# ខោនធី SONOMA
# មន្ត្រីគ្រប់គ្រងការបោះឆ្នោត

# ផែនការរដ្ឋបាលបោះឆ្នោត
# ខែវិច្ឆិកា ឆ្នាំ 2021


**County of Sonoma**
**Registrar of Voters**
**435 Fiscal Drive**
**Santa Rosa, CA 95403**
**(707) 565-6800**
**(800) 750-8683**
rov-info@sonoma-county.org
sonomacounty.ca.gov/vote

# មាតិកា

ផ្នែក 1៖ ផែនការអប់រំនិងទំនាក់ទំនងអ្នកបោះឆ្នោត ........ 4

I. ទិដ្ឋភាពទូទៅ ........ 4

II. ការទំនាក់ទំនងអ្នកបោះឆ្នោត & សហគមន៍ ........ 5

III. សេវាអ្នកបោះឆ្នោត ........ 10

1. ការកំណត់អត្តសញ្ញាណអ្នកបោះឆ្នោតក្រុមអ្នកប្រើភាសាជាតិភាគតិច ផ្នែក 4005(a)(10)(I)(i)(V) ........ 10
2. គណៈកម្មការប្រឹក្សាលទ្ធភាពចូលរួមផ្នែកភាសា ........ 11
3. សិក្ខាសាលាអប់រំ ........ 11
4. ប្រព័ន្ធផ្សព្វផ្សាយ/ការផ្សាយពាណិជ្ជកម្ម ........ 11
5. ឯកសារជាភាសាជំនួស ........ 12
6. ជំនួយពីរភាសានៅតាមមណ្ឌលបោះឆ្នោត ........ 13
1. គណៈកម្មការប្រឹក្សាលទ្ធភាពចូលរួមបោះឆ្នោត ........ 14
2. សិក្ខាសាលាអប់រំ ........ 15
3. ប្រព័ន្ធផ្សព្វផ្សាយ/ការផ្សាយពាណិជ្ជកម្ម ........ 15
4. ឯកសារតាមទម្រង់ជ្រើសរើស ........ 16
5. ចូលរួមបោះឆ្នោតពីចម្ងាយតាមសំបុត្រ (RAVBM) ........ 17
6. លទ្ធភាពចូលទៅកានមណ្ឌលបោះឆ្នោត ........ 18
7. ជម្រើសមកទទួលយកសន្លឹកឆ្នោត ........ 19
8. ការបោះឆ្នោតបន្ទាន់តាមសន្លឹកឆ្នោតផ្ញើតាមប៉ុស្ដិ៍ ........ 20

IV. ការឆ្លើយតបការឆកល្វែងក្នុងការចូលរួម ........ 20

V. ថវិកា ........ 22

ផ្នែក 2៖ ផែនការរដ្ឋបាលបោះឆ្នោត ........ 24

I. ទិដ្ឋភាពទូទៅ ........ 24

II. សកម្មភាពមុនការបោះឆ្នោត ........ 25

1. អ្នកវាយតម្លៃពត៌មានចុះឈ្មោះអ្នកបោះឆ្នោត (Clerk-Recorder Assessor IT, CRA-IT) ........ 25

2. ការស្វែងមតិបទពិសោធន៍គំរូ VCA ........ 26
III. សកម្មភាពបោះឆ្នោត & ការគាំទ្រ ........ 30
1. សៀវភៅណែនាំព័ត៌មានអ្នកបោះឆ្នោតខោនធី ........ 30
2. កញ្ចប់បោះឆ្នោតតាមសន្លឹកឆ្នោតផ្ញើតាមប៉ុស្តិ៍ ........ 31
3. ប័ណ្ណប្រៃសណីយ៍អ្នកបោះឆ្នោត ........ 31
4. គេហទំព័រ ROV ........ 31
1. បោះឆ្នោតតាមសំបុត្រ ........ 32
2. ការបោះឆ្នោតដែលអាចធ្វើបានតាមសំបុត្រ ........ 34
3. មណ្ឌលបោះឆ្នោត ........ 34
4. ហិបទម្លាក់សន្លឹកឆ្នោត ........ 38
IV. សកម្មភាពក្រោយការបោះឆ្នោត – សាធារណជនអាចសង្កេតដំណើរការបោះឆ្នោតណាមួយក៏បាន ........ 39

## ផ្នែក 1៖ ផែនការអប់រំនិងទំនាក់ទំនងអ្នកបោះឆ្នោត

### I. ទិដ្ឋភាពទូទៅ

ច្បាប់ជម្រើសអ្នកបោះឆ្នោត (Voter's Choice Act, VCA) រដ្ឋកាលីហ្វ័រញ៉ា តម្រូវឲ្យខោនធីបង្កើតឡើងនូវផែនការអប់រំនិងទំនាក់ទំនងអ្នកបោះឆ្នោត ដែលផ្តល់នូវតម្លាភាព និងផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតឲ្យគ្រប់ទិដ្ឋភាពទាំងអស់នៃច្បាប់ VCA។ នេះរួមបញ្ចូលទាំងសេវាកម្មនានា និងព័ត៌មានមាននៅតាមបណ្ឌលបោះឆ្នោតនិងទីតាំងហិបឆ្នោត និងព័ត៌មានកំណត់ជាក់លាក់ចំពោះអ្នកបោះឆ្នោតដែលមានពិការភាព និងអ្នកបោះឆ្នោតនិយាយភាសាភាគតិច។

ការប្រជុំជាសាធារណៈនឹងត្រូវធ្វើឡើងជាមួយនឹងអង្គការសហគមន៍ និងបុគ្គលទាំងឡាយ ដែលធ្វើការតស៊ូមតិជំនួសឲ្យ ឬ ផ្តល់សេវាកម្មទៅដល់ សហគមន៍ជនមានពិការភាពនិងសហគមន៍និយាយភាសាភាគតិច។ មន្ត្រីគ្រប់គ្រងការបោះឆ្នោត (Registrar of Voters, ROV) ខោនធី Sonoma នឹងរៀបចំសិក្ខាសាលាអប់រំជាសាធារណៈជាច្រើន។ ព្រឹត្តិការណ៍សាធារណៈទាំងអស់ត្រូវបានរៀបចំឡើងដោយខោនធី នឹងធ្វើឡើងតាមអនឡាញ ដោយសារតែការគំរាមកំហែងនៃជំងឺរាតត្បាតកូវីដ-១៩ នៅតែបន្តមាន ហើយនឹងអាចចូលរួមបានស្របទៅតាមច្បាប់ពលរដ្ឋអាមេរិកាំងមានពិការភាព (Americans with Disabilities Act, AD)។ ខ្លឹមសារ និងការផ្ញើសារនៃព្រឹត្តិការណ៍នឹងត្រូវបានបង្កើតឡើងដោយមានការចូលរួមពីគណៈកម្មាធិការ គណៈកម្មាធិការប្រឹក្សាលទ្ធភាពប្រើប្រាស់ភាសា Language Accessibility Advisory Committee, LAAC) និង VAAC។

ផែនការនេះនឹងបញ្ជាក់ពីគោលបំណងទំនាក់ទំនងរបស់ អ្នកកាន់កាប់បញ្ជីអ្នកបោះឆ្នោត (Registrar of Voters, ROV) ដែលត្រូវឲ្យច្បាស់ ដើម្បីអនុវត្តគំរូបោះឆ្នោត ច្បាប់ជម្រើសរបស់អ្នកបោះឆ្នោត (Voter's Choice Act, VCA) សម្រាប់ការបោះឆ្នោតជាពិសេសសមស្របនៅក្នុងឆ្នាំ 2021 ហើយនឹងដំណើរឆ្ពោះទៅមុខ។ បញ្ជីព្រឹត្តិការណ៍ដែលនឹងចូលមកដល់ ត្រូវបានបោះពុម្ពផ្សាយនៅលើ គេហទំព័ររបស់ ROV។ សម្រាប់ព្រឹត្តិការបន្ថែម គំនិតសម្រាប់ឱកាសទំនាក់ទំនង ឬ អនុសាសន៍នានាដើម្បីលើកកំពស់ផែនការរដ្ឋបាលបោះឆ្នោតនេះ សូមផ្ញើអ៊ីម៉ែលទៅកាន់ rov-info@sonoma-county.org។ ផែនការនេះនឹងត្រូវដាក់បញ្ជូនទៅកាន់ការិយាល័យលេខារដ្ឋសម្រាប់ការពិនិត្យឡើងវិញ និងការអនុម័តិជាស្ថាពរ។ ទោះជាយ៉ាងណា មតិត្រឡប់ទាក់ទងនឹងផែនការនេះ និងការខិតខំប្រឹងប្រែងរបស់ ROV នឹងត្រូវបានទទួលយកនៅគ្រប់ពេលទាំងអស់។

## II. <u>ការទំនាក់ទំនងអ្នកបោះឆ្នោត & សហគមន៍</u>

### A. ការរៀបចំសារសម្រាប់ឆ្នាំ2022

ROV បានបង្កើតឡើងនូវចំណុចបង្កើតសារទាំងឡាយដូចខាងក្រោម ដែលនឹងប្រើវាឡង់នៅក្នុងគ្រប់ឯកសារផ្សព្វផ្សាយនិងអប់រំទាំងអស់៖

*ការបោះឆ្នោតឆ្នាំ 2022 (កាលបរិច្ឆេទ TBD)*

- បោះឆ្នោតមុនដើម្បីបញ្ចៀសការតម្រង់ជួរ
- ការផ្ញើតាមប្រៃសណីយ៍បច្ចុប្បន្នត្រូវបង់ថ្លៃនៅលើស្រោមសំបុត្រផ្ញើត្រឡប់សន្លឹកឆ្នោតបោះតាមសំបុត្រ
- ចុះឈ្មោះដើម្បីតាមដានសន្លឹកឆ្នោតរបស់តាម wheresmyballot.sos.ca.gov
- សូមស្វែងរកបញ្ជីទីតាំងបោះឆ្នោត និងកាលបរិច្ឆេទនិងពេលវេលាបោះឆ្នោត ព្រមទាំងហិបទម្លាក់សន្លឹកឆ្នោតនៅលើគេហទំព័ររបស់យើង sonomacounty.ca.gov/vote
- សូមពិនិត្យមើលស្ថានភាពការចុះឈ្មោះបោះឆ្នោតរបស់អ្នក
- ប្រើមគ្គុទ្ទេសក៍ព័ត៌មានអ្នកបោះឆ្នោតតាមអ៊ីនធឺណិត (Voter Information Guide, VIG) ដើម្បីពិនិត្យឯកសារ និងសន្លឹកឆ្នោតយោងរបស់អ្នក។

*7 មិថុនា 2022 ការបោះឆ្នោតបឋមជ្រើសរើសអភិបាលរដ្ឋ៖*

- បោះឆ្នោតមុនដើម្បីបញ្ចៀសការតម្រង់ជួរ
- ការផ្ញើតាមប្រៃសណីយ៍បច្ចុប្បន្នត្រូវបង់ថ្លៃនៅលើស្រោមសំបុត្រផ្ញើត្រឡប់សន្លឹកឆ្នោតបោះតាមសំបុត្រ
- ការបោះឆ្នោតបឋមជ្រើសរើសអភិបាលរដ្ឋនៅឆ្នាំ 2022 ត្រូវបានប្តូរទៅខែមិនថុនា
- ចុះឈ្មោះដើម្បីតាមដានសន្លឹកឆ្នោតរបស់តាម wheresmyballot.sos.ca.gov
- សូមស្វែងរកបញ្ជីទីតាំងបោះឆ្នោត និងកាលបរិច្ឆេទនិងពេលវេលាបោះឆ្នោត ព្រមទាំងហិបទម្លាក់សន្លឹកឆ្នោតនៅលើគេហទំព័ររបស់យើង sonomacounty.ca.gov/vote
- សូមពិនិត្យមើលស្ថានភាពការចុះឈ្មោះបោះឆ្នោតរបស់អ្នក

- ប្រើមគ្គុទ្ទេសក៍ព័ត៌មានអ្នកបោះឆ្នោតតាមអ៊ីនធឺណិត (VIG) ដែលអាចចូលប្រើបាន ដើម្បីពិនិត្យឯកសារ និងសន្លឹកឆ្នោតយោងរបស់អ្នក។

*8 វិច្ឆិកា 2022 ការបោះឆ្នោតបង្រួមៈ*

- បោះឆ្នោតមុនដើម្បីបញ្ជាសការតម្រង់ជួរ
- ការផ្ញើតាមប្រៃសណីយ៍បច្ចុប្បន្នត្រូវបង់ថ្លៃនៅលើស្រោមសំបុត្រផ្ញើត្រឡប់សន្លឹកឆ្នោតបោះតាមសំបុត្រ
- ចុះឈ្មោះដើម្បីតាមដានសន្លឹកឆ្នោតរបស់តាម wheresmyballot.sos.ca.gov
- សូមស្វែងរកបញ្ជីទីតាំងបោះឆ្នោត និងកាលបរិច្ឆេទនិងពេលវេលាបោះឆ្នោត ព្រមទាំងហិបទម្លាក់សន្លឹកឆ្នោតនៅលើគេហទំព័ររបស់យើង sonomacounty.ca.gov/vote
- សូមពិនិត្យមើលស្ថានភាពការចុះឈ្មោះបោះឆ្នោតរបស់អ្នក
- ប្រើមគ្គុទ្ទេសក៍ព័ត៌មានអ្នកបោះឆ្នោតតាមអ៊ីនធឺណិត (VIG) ដើម្បីពិនិត្យឯកសារ និងសន្លឹកឆ្នោតយោងរបស់អ្នក

ចំណុចទាំងនេះនឹងត្រូវបែងចែកតាមរយៈប្រព័ន្ធទំនាក់ទំនងសង្គម ដៃគូ នៅក្នុងការទំនាក់ទំនងរបស់យើងជាមួយនឹងសាធារណជន និងនៅលើខិតប័ណ្ណផ្សព្វផ្សាយរបស់យើង និងប័ណ្ណផ្តល់ព័ត៌មានចែកជូន។ ROV នឹងបន្តនូវការខិតខំប្រឹងប្រែងជាប់ជានិច្ច ដើម្បីធានា សាធារណជនដឹងពីរបៀបចុះឈ្មោះបោះឆ្នោត និងចូលរួមបោះឆ្នោតដែលនឹងចូលមកដល់ និងសេវាកម្មដែលមានទាំងឡាយនៅតាមទីតាំងហិបទម្លាក់សន្លឹកឆ្នោត និងមណ្ឌលបោះឆ្នោត។

ការបញ្ចេញសារបន្ថែម នឹងត្រូវកំណត់ដោយ ROV ក្រោយពីការពិនិត្យទៅលើសំណួរនិងការហៅទូរសព្ទចូលរបស់អ្នកបោះឆ្នោត ការប្រជុំតាមសហគមន៍ និងលទ្ធផលស្ទង់មតិបទពិសោធន៍មណ្ឌលបោះឆ្នោត ក្រោយពីការបោះឆ្នោត VCA លើកទីមួយត្រូវបានធ្វើឡើង។

ROV នឹងធ្វើការជាដៃគូជាមួយនឹងអង្គការសហគមន៍ ទីភ្នាក់ងាររដ្ឋ សាលារៀន និងក្រុមទាំងឡាយផ្សេងទៀត ដើម្បីលើកកម្ពស់ការយល់ដឹងពីគំរូមណ្ឌលបោះឆ្នោត។ នេះនឹងរួមបញ្ចូលគ្នានូវយុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយដ៏ទូលំទូលាយប្រើប្រាស់ការផ្ញើតាមប្រៃសណីយ៍ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានវិទ្យុ ប្រព័ន្ធផ្សព្វផ្សាយសង្គម ប្រព័ន្ធផ្សព្វផ្សាយដែលទទួលបានជាសាធារណៈ និងការជូនដំណឹ

ងពីសេវាសាធារណៈ (public service announcements, PSA)។ យុទ្ធនាការនឹងផ្សព្វផ្សាយប្រព័ន្ធទូរសព្ទផ្តល់ជំនួយដល់អ្នកបោះឆ្នោតដោយមិនគិតថ្លៃ ផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតដែលមានពិការភាព ពីរបៀបទទួលបានសន្លឹកឆ្នោតទៅតាមទម្រង់ដែលអាចបោះបាន និងផ្តល់សេវាពហុភាសាដល់អ្នកបោះឆ្នោតនិយាយភាសាភាគតិច។

ROV នឹងចាប់ដៃគូជាមួយនឹងអង្គការសហគមន៍ទាំងឡាយដើម្បីចូលរួមព្រឹត្តិការសហគមន៍ និងផ្តល់ការអប់រំ និងឱកាសផ្សព្វផ្សាយដល់អ្នកបោះឆ្នោត។

ពេលវេលាកំណត់ជាទូទៅសម្រាប់ផែនការទំនាក់ទំនងប្រតិបត្តិរបស់ ROV អាចរកបាននៅក្នុងឧបសម្ព័ន្ធ F។

## B. សហគមន៍ដៃគូ

ROV នឹងផ្តល់ព័ត៌មានអំពីគំរូមណ្ឌលបោះឆ្នោតទៅដល់សហគមន៍ដៃគូ ដើម្បីជួយក្នុងការផ្សព្វផ្សាយទៅដល់អ្នកបោះឆ្នោត។ ROV នឹងចូលរួមព្រឹត្តិការសហគមន៍ ធ្វើបទបង្ហាញទៅដល់អង្គការនានា និងបណ្តុះបណ្តាលបុគ្គលនិងក្រុមនានាដែលចាប់អារម្មណ៍ ដើម្បីជួយដល់ការអប់រំនិងការផ្សព្វផ្សាយ។ បញ្ជីនៃសហគមន៍ដៃគូអាចរកឃើញមាននៅក្នុងឧបសម្ព័ន្ធ A។

សហគមន៍ដៃគូនិងសាធារណជន អាចជួយបានតាមមធ្យោបាយផ្សេងៗគ្នាដូចជា៖

- ចែកចាយនូវព័ត៌មានបោះឆ្នោតត្រឹមត្រូវមិនប្រកាន់បក្សពួកនៅតាមប្រព័ន្ធទំនាក់ទំនងសង្គម
- បង្ហោះព័ត៌មានបោះឆ្នោតនិងដំណភ្ជាប់ទៅកាន់គេហទំព័ររបស់យើង sonomacounty.ca.gov/vote នៅក្នុងព្រឹត្តិបត្តិសហគមន៍ ឬ គេហទំព័រ
- ដាក់តាំងនូវខិតប័ណ្ណផ្សព្វផ្សាយនិងឯកសារផ្តល់ជូននៅតាមការិយាល័យ ឬ ទីតាំងទាំងឡាយដែលសាធារណជនឧស្សាហ៍ចុះឡើង
- ជួយក្នុងការចែកចាយព័ត៌មាន ឯកសារផ្សព្វផ្សាយ និងខិតប័ណ្ណផ្សព្វផ្សាយ រួមបញ្ចូលទាំងចំណុចសារជាក់លាក់ពីការបោះឆ្នោត
- ចូលរួមក្នុងព្រឹត្តិការណ៍ផ្សព្វផ្សាយសហគមន៍ពីចម្ងាយ។ ចូលរួមក្នុងការប្រជុំក្រុមប្រឹក្សាស្តីពីការបង្កើតសារ ការព្រួយបារម្ភ ឬសំណួររួមពីសាធារណជន
- អញ្ជើញអ្នកតំណាងការបោះឆ្នោតពី ROV ដើម្បីបង្ហាញព័ត៌មានបោះឆ្នោតដែលមិនប្រកាន់បក្សពួកទៅដល់ក្រុមអតិថិជន អតិថិជន សមាជិក ឬ ពលរដ្ឋក្នុងមូលដ្ឋាន។

កញ្ចប់ឧបករណ៍អនឡាញនឹងត្រូវបង្កើតឡើង និងដាក់ឲ្យទាញយកនៅលើគេហទំព័រ ROV sonomacounty.ca.gov/vote។ កញ្ចប់ឧបករណ៍នេះនឹងរួមបញ្ចូលនូវក្រាហ្វ ខិតប័ណ្ណព័ត៌មាន ខិតប័ណ្ណផ្សព្វផ្សាយ និងបទបង្ហាញពី VCA។ ឯកសារផ្សព្វផ្សាយបោះពុម្ពអាចនឹងត្រូវផ្តល់ទៅដល់ក្រុម ឬអង្គការដោយមិនគិតថ្លៃ។ សូមទាក់ទង rov-info@sonoma-county.org សម្រាប់ព័ត៌មានបន្ថែម។

**C. វិទ្យាល័យ & ឧត្តមសិក្សា**

ROV នឹងរៀបចំការទំនាក់ទំនងទៅកាន់វិទ្យាល័យទៅតាមការស្នើសុំ ដើម្បីអប់រំដល់និស្សិតអំពីដំណើរការបោះឆ្នោត។ ROV នឹងបន្តធ្វើជាដៃគូជាមួយនឹងមហាវិទ្យាល័យក្នុងមូលដ្ឋាននៅទូទាំងខោនធី ដើម្បីផ្តល់ព័ត៌មាន និងធនធានទាំងឡាយអំពីដំណើរការបោះឆ្នោត គំរូមណ្ឌលបោះឆ្នោត និងការបោះឆ្នោតដែលនឹងចូលមកដល់តាមរយៈបទបង្ហាញ ព្រឹត្តិការតាមសាលា និងការជម្រុញការចុះឈ្មោះ។

**D. បណ្តាញបោះឆ្នោតជាលក្ខណបុគ្គល**

សកម្មភាពទំនាក់ទំនងនិងអប់រំមិនត្រូវបានកម្រិតចំពោះអង្គការនោះទេ។ បុគ្គលបោះឆ្នោតដើរតួជាផ្នែកមួយនៃបណ្តាញគាំទ្រផ្តល់ព័ត៌មានដល់ ROV ខោនធី Sonoma ពីឧបសគ្គទាំងឡាយចំពោះការបោះឆ្នោត និងជួយផ្តល់ ដំណោះស្រាយ ដើម្បីធានានូវការយល់ដឹងទូលំទូលាយពីគំរូមណ្ឌលបោះឆ្នោត។ ROV នឹងផ្តល់នូវប័ណ្ណស្ទង់មតិបទពិសោធន៍អ្នកបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោត ដើម្បីទទួលបានមតិយោបល់អំពីបទពិសោធន៍របស់អ្នកបោះឆ្នោត។ សំណួរការស្ទង់មតិរួមបញ្ចូលទាំងការចូលទៅកាន់មណ្ឌលបោះឆ្នោត និងការប្រើប្រាស់សេវាភាសាក្នុងចំណោមសំណួរទាំងឡាយផ្សេងទៀត។

សំណួរឬមតិយោបល់ទាំងឡាយពីសាធារណជនអាចត្រូវបានចែករំលែកនៅគ្រប់ពេលតាមការផ្ញើអ៊ីម៉ែលមក rov-info@sonoma-county.org.

**E. លេខទំនាក់ទំនងអ្នកបោះឆ្នោតដោយផ្ទាល់**

ROV នឹងផ្ញើប័ណ្ណប្រៃសណីយ៍ដោយផ្ទាល់ពីទៅកាន់អ្នកបោះឆ្នោតខោនធី Sonoma ដែលចុះឈ្មោះម្នាក់ៗ ដើម្បីជូនដំណឹងដល់ពួកគេពីការផ្លាស់ប្តូរស្ថិតក្រោមគំរូបោះឆ្នោត VCA។ គោលបំណងទូទៅនៃប័ណ្ណប្រៃសណីយ៍ទំនាក់ទំនងផ្ទាល់ទាំងនេះ ត្រូវផ្តល់ព័ត៌មានពីការបោះឆ្នោតដែលនឹ

ងចូលមកដល់ ការផ្ដល់ឲ្យមាននូវប្រព័ន្ធទូរសព្ទជំនួយអ្នកបោះឆ្នោតដោយឥតគិតថ្លៃរបស់ ROV និងជម្រើសក្នុងការបោះឆ្នោត។

- *ប័ណ្ណប្រៃសណីយ៍ទីមួយ៖* ការផ្ញើជូនតាមប្រៃសណីយ៍លើទីមួយនឹងត្រូវធ្វើឡើងប្រមាណ 55 ថ្ងៃនៅមុនការបោះឆ្នោតនីមួយៗ ធ្វើការរំឭកដល់អ្នកបោះឆ្នោតឲ្យរង់ចាំមើលសន្លឹកឆ្នោតបោះតាមប្រៃសណីយ៍ និងដើម្បីពិនិត្យមើលស្ថានភាពរបស់គេ និងត្រូវប្រាកដ ពួកគេត្រូវបានចុះឈ្មោះត្រឹមត្រូវ ដើម្បីឲ្យប្រាកដ ពួកគេទទួលបានសន្លឹកឆ្នោតតាមសំបុត្រ។
- *ប័ណ្ណប្រៃសណីយ៍ទីពីរ៖* ការផ្ញើសំបុត្រទីពីរនឹងត្រូវធ្វើឡើងប្រមាណជា 22 ថ្ងៃមុនការបោះឆ្នោត ដើម្បីរំឭកដល់អ្នកបោះឆ្នោតនៅពេលដែលមណ្ឌលបោះឆ្នោតបើកដំណើរការ ជម្រើសទាំងឡាយសម្រាប់ការផ្ញើត្រឡប់មកវិញនូវសន្លឹកឆ្នោតរបស់គេ រួមទាំងការរំឭកឲ្យចុះហត្ថលេខាលើស្រោមសំបុត្ររបស់ពួកគេ និងដើម្បីបោះឆ្នោតឲ្យបានមុន និងបញ្ចៀសនូវការតម្រង់ជួរនៅថ្ងៃបោះឆ្នោត។

អ្នកបោះឆ្នោទទាំងអស់ដែលបានចុះឈ្មោះរួចនឹងទទួលបាននូវប័ណ្ណប្រៃសណយ៍ជាភាសាអង់គ្លេស។ ប្រសិនបើអ្នកបោះឆ្នោតមានបំណងទទួលបាននូវឯកសារផ្សព្វផ្សាយជាភាសាអេស្ប៉ាញ តាហ្គាឡុក វៀតណាម ឬ ខ្មែរនោះ ពួកគេអាចទាក់ទងការិយាល័យរបស់យើង ដើម្បីស្នើសុំឯកសារបកប្រែ។

ប័ណ្ណប្រៃសណីយ៍ពង្រាងគំរូ ត្រូវបានដាក់ចូលទៅក្នុងឧបសម្ព័ន្ធ B។

## F. គណៈកម្មការប្រឹក្សា

ROV នឹងបង្កើតគណៈកម្មការចំនួនពីរ ដើម្បីជួយក្នុងការបង្កើត និងការអនុវត្តការខិតខំប្រឹងប្រែងទំនាក់ទំនងនិងអប់រំផែនការរដ្ឋបាលបោះឆ្នោត៖

- គោលបំណង របៀបវារៈ និងកំណត់ហេតុប្រជុំរបស់គណៈកម្មការប្រឹក្សាលទ្ធភាពចូលរួមការបោះឆ្នោត (VAAC) ត្រូវបានដាក់នៅលើគេហទំព័រ VAAC។
- គោលបំណង របៀបវារៈ និងកំណត់ហេតុប្រជុំគណៈកម្មការប្រឹក្សាលទ្ធភាពចូលរួមផ្នែកភាសា (LAAC) មានដាក់នៅលើគេហទំព័រ LAAC។

គណៈកម្មការទាំងនេះនឹងជួយដល់លទ្ធភាពចូលរួម ភាសានិងតម្រូវការសហគមន៍ និងផ្ដល់យោបល់ដល់ ROV ពីទិដ្ឋភាពផ្សេងៗគ្នានៃផែនការអប់រំនិងទំនាក់ទំនងអ្នកបោះឆ្នោត។

សម្រាប់ព័ត៌មានបន្ថែមអំពីគណៈកម្មការណាមួយ សូមអ៊ីម៉ែលទៅកាន់ rov-info@sonoma-county.org។

**G. ការជូនដំណឹងពីសេវាសាធារណៈ (PSA) & ប្រព័ន្ធផ្សព្វផ្សាយ**

ROV នឹងប្រើប្រាស់ PSA នៅក្នុងទម្រង់ទាំងរូបភាពនិងសម្លេង ដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតពីការបោះឆ្នោតដែលនឹងចូលមកដល់ និងពីប្រព័ន្ធទូរសព្ទផ្តល់ជំនួយដល់អ្នកបោះឆ្នោតដោយឥតគិតថ្លៃ។ PSA នឹងត្រូវចែកចាយតាមរយៈទូរទស្សន៍ វិទ្យុ កាសែត និងប្រព័ន្ធទំនាក់ទំនងសង្គម ដើម្បីឲ្យទៅដល់អ្នកបោះឆ្នោតទាំងអស់ រួមទាំងអ្នកបោះឆ្នោតដែលមានពិការភាពនិងអ្នកបោះឆ្នោតនិយាយភាសាភាគតិចផងដែរ។ LAAC និង VAAC នឹងផ្តល់ជំនួយដល់ការផលិតនូវខ្លឹមសារ PSA។ PSA នឹងផ្តល់ដល់បណ្តាញផ្សព្វផ្សាយទាំងឡាយដែលត្រូវរាយក្នុងឧបសម្ព័ន្ធ C។ ពេលវេលាកំណត់ជាទូទៅសម្រាប់ PSAs និងព័ត៌មានទំនាក់ទំនងជាមួយនឹងបណ្តាញព័ត៌មានផ្សេងទៀតមាននៅក្នុងឧបសម្ព័ន្ធ F។

## III. <u>សេវាអ្នកបោះឆ្នោត</u>

**A. សេវាកម្មសម្រាប់អ្នកបោះឆ្នោតដែលមានសមត្ថភាពភាសាអង់គ្លេសមានកម្រិត**

ខោនធី Sonoma បច្ចុប្បន្នពុំតម្រូវឲ្យផ្តល់ឯកសារបោះឆ្នោតបកប្រែទេ ក្រោមច្បាប់សិទ្ធិអ្នកបោះឆ្នោតឆ្នាំ 1965។ ទោះជាយ៉ាងណា ច្បាប់រដ្ឋតម្រូវឲ្យខោនធីផ្តល់ជំនួយផ្នែកភាសា និងច្បាប់ចតចម្លងបកប្រែនៃសន្លឹកឆ្នោតផ្លូវការជាភាសាដូចតទៅ៖ អេស្ប៉ាញ វៀតណាម ហ្គាតាឡុក និងខ្មែរនៅតាមតំបន់ជាក់លាក់។

1. *ការកំណត់អត្តសញ្ញាណអ្នកបោះឆ្នោតក្រុមអ្នកប្រើភាសាជាតិភាគតិច ផ្នែក 4005(a)(10)(I)(i)(V)*

   ROV កំណត់ការនិយមប្រើភាសារបស់អ្នកបោះឆ្នោត ដូចបានបង្ហាញប្រាប់ដោយអ្នកអ្នកបោះឆ្នោតនៅក្នុងផ្នែក “ព័ត៌មានអ្នកបោះឆ្នោតតាមជម្រើស (Optional Voter Information)” នៅលើទម្រង់បែបបទចុះឈ្មោះអ្នកបោះឆ្នោត។ អ្នកបោះឆ្នោតដែលប្រើភាសាភាគតិច ក៏អាចផ្ញើអ៊ីម៉ែល ឬទូរសព្ទទៅ ROV ផងដែរដើម្បីបំពេញតាមការនិយមប្រើភាសារបស់ពួកគេ។ ROV បញ្ចូលនិងរក្សាទុកទិន្នន័យនេះនៅក្នុង EMS របស់យើង។ ម៉្យាងទៀត ROV ទទួលបានព័ត៌មានអំពីសហគមន៍ក្រុមភាសាភាគតិចអំពីសហគមន៍ក្រុមអ្នកប្រើភាសាភាគតិច ពីការិយាល័យជំរឿនសហរដ្ឋអាមេរិក។

2. *គណៈកម្មការប្រឹក្សាលទ្ធភាពចូលរួមផ្នែកភាសា*
ROV បានបង្កើត LAAC ឡើងជាគណៈកម្មការប្រឹក្សាពលរដ្ឋ ដើម្បីផ្តល់អនុសាសន៍សម្រាប់ការលើកកម្ពស់លទ្ធភាពចូលរួមផ្នែកភាសាចំពោះការបោះឆ្នោតនិងឯកសារបោះឆ្នោត។ LAAC និងត្រូវរៀបចំឡើងឲ្យផ្តល់យោបល់និងជួយក្នុងការបំពេញទៅតាមលក្ខខណ្ឌតម្រូវផ្នែកភាសាកំណត់ដោយរដ្ឋ។ ROV នឹងធ្វើការជាមួយនឹងសមាជិក LAAC និងដៃគូសហគមន៍ ដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតពីតម្រូវការផ្នែកភាសា។

3. *សិក្ខាសាលាអប់រំ*
ជាផ្នែកមួយនៃការខិតខំប្រឹងប្រែងផ្សព្វផ្សាយរបស់ខ្លួន ROV នឹងបន្តនូវការផ្សព្វផ្សាយរបស់ខ្លួនទៅកាន់អ្នកបោះឆ្នោតនិយាយភាសាភាគតិច។ ROV នឹងធ្វើការជាមួយនឹងសមាជិក LAAC និងសហគមន៍ដៃគូ ដើម្បីផ្តល់ដល់អ្នកបោះឆ្នោតនូវជំនួយផ្នែកភាសានៅតាមសិក្ខាសាលាអប់រំ។ សិក្ខាសាលានឹងត្រូវរៀបកាលវិភាគទៅតាមតម្រូវការចាំបាច់។ ការអញ្ជើញចូលរួមសិក្ខាសាលាទាំងនេះ នឹងត្រូវបានផ្តល់ជូនតាមអ៊ីម៉ែលទៅកាន់អ្នកទាំងឡាយផ្សេងៗគ្នា និងអង្គការទាំងឡាយដែលបានទំនាក់ទំនងរួចជាស្រេចទាក់ទងដល់សមាជិកភាពសក្តានុពលនៅក្នុង LAAC និង VAAC របស់យើង នៅលើគេហទំព័រហ្វេសប៊ុករបស់យើង និងដោយមានជំនួយពីក្រុមការិយាល័យទំនាក់ទំនងរបស់រដ្ឋបាលខោនធីរបស់យើង។ នៅតាមសិក្ខាសាលាទាំងនេះ ROV នឹងផ្តល់នូវ៖

- ឧទាហរណ៍នៃសន្លឹកឆ្នោតតាមទូរសារបកប្រែដោយមានសេចក្តីណែនាំដល់អ្នកបោះឆ្នោត ដែលគេស្គាល់ថាគោលការណ៍ណែនាំការបកប្រែសន្លឹកឆ្នោត។
- ឯកសារ VCA បកប្រែជាភាសាតម្រូវដោយរដ្ឋទាំងអស់សម្រាប់ខោនធី Sonoma។

4. *ប្រព័ន្ធផ្សព្វផ្សាយ/ការផ្សាយពាណិជ្ជកម្ម*
សេចក្តីប្រកាសព័ត៌មានដែលបានចែកចាយទូទាំងខោនធី Sonoma នឹងប្រកាសពីប្រព័ន្ធទូរសព្ទផ្តល់ជំនួយដល់អ្នកបោះឆ្នោតដោយឥតគិតថ្លៃ ដែលនឹងផ្តល់ជំនួយជាភាសាអង់គ្លេស។ សេចក្តីប្រកាសព័ត៌មានក៏នឹងត្រូវបានចែកចាយផងដែរទៅដល់បណ្តាញប្រព័ន្ធផ្សព្វផ្សាយផ្សេងៗជាភាសាអេស្ប៉ាញផងដែរ រួមមាន Latino Service Providers, El Patron Radio, KBBF, Sonoma Media Investments និង La Voz Newspaper ។ យើងក៏នឹងមានសេវាអ្នកបកប្រែតាមទូរសព្ទផ្តល់ជូនតាមរយៈការិយាល័យលេខារដ្ឋ ដែលអាចផ្តល់ការបកប្រែមិនត្រឹមតែភាសាកំណត់ដោយរដ្ឋរបស់យើង អេស្ប៉ាញ វៀតណាម តាហ្គាឡុក

និងខ្មែរប៉ុណ្ណោះទេ តែថែមទាំងភាសាជាច្រើនផ្សេងទៀតផងដែរ។ បន្ថែមលើនេះ ការផ្សាយពាណិជ្ជកម្មតាមប្រព័ន្ធផ្សព្វផ្សាយជាភាសាអេស្ប៉ាញ តាហ្កាឡុក និងខ្មែរ នឹងត្រូវទិញដើម្បីផ្សព្វផ្សាយពីសេវាអ្នកបកប្រែតាមទូរសព្ទ ដែលមាននៅក្នុងខោនធី។ បញ្ជីរាយនាមពេញលេញនៃដៃគូប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានរួមបញ្ចូលនៅក្នុងឧបសម្ព័ន្ធ C។

5. *ឯកសារជាភាសាជំនួស*

រាល់អ្នកបោះឆ្នោតខោនធី Sonoma ដែលបានចុះឈ្មោះរួច នឹងត្រូវបានផ្ញើទៅឲ្យនូវសន្លឹកឆ្នោតបោះតាមសំបុត្រ (Vote by Mail, VBM) ចាប់ផ្តើមឡើងយ:ពេល 29 ថ្ងៃមុនថ្ងៃបោះឆ្នោត។ សន្លឹកឆ្នោតផ្លូវការទាំងអស់ជាភាសាអង់គ្លេសតែមួយ។ ស្រោមសំបុត្របញ្ជូនត្រឡប់ត្រូវបានផ្តល់ជាភាសាអង់គ្លេស ឯកសារបោះពុម្ពផ្សាយពីគោលការណ៍ណែនាំព័ត៌មានអ្នកបោះឆ្នោតខោនធី និងមណ្ឌលបោះឆ្នោត និងហិបទម្លាក់សន្លឹកឆ្នោត នឹងជាភាសាអង់គ្លេសទាំងអស់។

ច្បាប់ថតចម្លងតាមទូរសារនៃសន្លឹកឆ្នោតផ្លូវការ ត្រូវបានកំណត់ថាជា "គោលការណ៍ណែនាំការបកប្រែសន្លឹកឆ្នោត" នៅក្នុងខោនធី Sonoma ត្រូវបានបកប្រែជាភាសាអេស្ប៉ាញ វៀតណាម តាហ្កាឡុក និងខ្មែរ។ ស្ថិតក្រោមក្រមបោះឆ្នោតរដ្ឋកាលីហ្វ័រញ៉ា 14201 សន្លឹកឆ្នោតតាមទូរសារត្រូវតែបោះនៅតាមមណ្ឌលបោះឆ្នោតជាភាសាជាក់លាក់ ប្រសិនបើវាត្រូវបានកំណត់ថាមាន 3% ឬច្រើនជាងនេះនៃក្រុមអ្នកនិយាយភាសាភាគតិចមាននៅក្នុងឬជុំវិញតំបន់នោះមានសមត្ថភាពភាសាអង់គ្លេសមានកម្រិតនោះ។ សន្លឹកឆ្នោតតាមទូរសារត្រូវបានផ្ញើតាមសំបុត្រទៅកាន់អ្នកបោះឆ្នោតដែលស្នើសុំសន្លឹកឆ្នោតតាមទូរសារជាភាសានោះហើយរស់នៅក្នុងតំបន់ដែលត្រូវបានកំណត់នោះ។ អ្នកបោះឆ្នោតស្ថិតនៅក្រៅតំបន់កំណត់ ក៏អាចទាក់ទងទៅកាន់ ROV បានផងដែរ ដើម្បីស្នើសុំសន្លឹកឆ្នោតតាមទូរសារឲ្យផ្ញើទៅកាន់ពួកគេដោយអ៊ីម៉ែល rov-absentee@sonoma-county.org ឬ ហៅទូរសព្ទទៅលេខ (707) 565-6800។ បន្ថែមលើនេះ គោលការណ៍ណែនាំពីការបកប្រែសន្លឹកឆ្នោតក៏នឹងមានផ្តល់ជូននៅគ្រប់មណ្ឌលបោះឆ្នោត និងចំនួនច្បាប់ថតចម្លងបន្ថែមអាចស្នើសុំបាន និងផ្តល់ដោយមន្ត្រីជំនួយតាមគោលដៅតាមការចាំបាច់។

គ្រប់អ្នកបោះឆ្នោតទាំងអស់ អាចស្នើសុំសន្លឹកឆ្នោតជំនួសថ្មីបានដោយទូរសព្ទតាមលេខ (707) 565-6800 ឬ (800) 750-8683 ដោយការផ្ញើអ៊ីម៉ែលនូវសំណើទៅកាន់ rov-absentee@sonoma-county.org, ដោយការផ្ញើទូរសារនូវសំណើទៅលេខ ( 707 ) 565-6843, ដោយការទៅកាន់មណ្ឌលបោះឆ្នោត ការិយាល័យ ROV ឬ តាមរយ:កា

រចូលរួមបោះឆ្នោតពីចម្ងាយតាមអនឡាញតាមប្រព័ន្ធសំបុត្រ (Remote Accessible Vote by Mail, RAVBM) ដែលមានជាភាសាអង់គ្លេស។

6. *ជំនួយពីរភាសានៅតាមមណ្ឌលបោះឆ្នោត*

ស្ថិតក្រោមក្រមបោះឆ្នោតរដ្ឋកាលីហ្វ័រញ៉ា 12303 កិច្ចខិតខំប្រឹងប្រែងសមស្របត្រូវតែធ្វើឡើងទៅកាន់បុគ្គលិកជាមន្ត្រីបោះឆ្នោតនិយាយពីរភាសានៅតាមទីតាំងដែលបានកំណត់នៅទូទាំងខោនធី Sonoma ដែលមានជាជនគ្រប់អាយុបោះឆ្នោតមានសមត្ថភាពភាសាអង់គ្លេសមានកម្រិតចំនួន 3% ឬច្រើនជាងនេះ។ ខោនធីនីមួយៗនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា មានវិធីសាស្ត្រជាក់លាក់របស់ខ្លួនសម្រាប់កំណត់ថាតើតំបន់ណាដែលតម្រូវឲ្យមានមន្ត្រីបោះឆ្នោតនិយាយពីរភាសា។ សំណុំព័ត៌មានអ្នកបោះឆ្នោតដូចជា ទីកន្លែងកំណើត កោត្តនាម និងភាសាតាមការបេញចិត្ត ត្រូវប្រើប្រាស់ដើម្បីកំណត់ពីតំបន់ដែលជំនួយពីរភាសាអាចត្រូវចាំបាច់នោះ។ ព័ត៌មានជំរឿន និងការស្ទង់មតិសហគមន៍អាមេរិកាំង ដោយវាអនុវត្តបានចំពោះក្រមបោះឆ្នោត 14201 និង 12303 ត្រូវបានប្រើដើម្បីកំណត់តំបន់ដែលឆ្លើយតបនឹងកម្រិតកំណត់ 3%។

- ក្រុមប្រឹក្សាយោបល់៖ ROV នឹងពិចារណាមតិត្រឡប់និងសំណូមពរនានាអំពីតំបន់ដែលអាចនឹងមានតម្រូវការជំនួយពីរភាសាបន្ថែមពីក្រុមប្រឹក្សាយោបល់ដូចជា LAAC របស់ខោនធី Sonoma។
- ក្រុមតស៊ូមតិ៖ ROV នឹងពិភាក្សាជាមួយនឹងក្រុមសហគមន៍និងអង្គការផ្សេងៗគ្នាទាំងឡាយ ដែលតស៊ូមតិឲ្យមានការចូលរួមបានផ្នែកភាសានៅទូទាំងខោនធី Sonoma។ យើងប្រមើលឃើញថា ក្រុមទាំងនេះនឹងជួយដល់ ROV ក្នុងការកំណត់ចំនួនប្រជាជននិយាយភាសាភាគតិចនៅក្នុងខោនធី Sonoma។

មណ្ឌលបោះឆ្នោតដែលតម្រូវឲ្យមានជំនួយផ្នែកភាសា ត្រូវបានកំណត់ដោយលេខារដ្ឋកាលីហ្វ័រញ៉ាតាមរយៈទិន្នន័យជំរឿនអាមេរិកាំង។ បញ្ជីជំនួយផ្នែកភាសាមានទៅតាមមណ្ឌលបោះឆ្នោតនីមួយៗ នឹងត្រូវបោះពុម្ពនៅក្នុងគោលការណ៍ណែនាំព័ត៌មានអ្នកបោះឆ្នោតខោនធី (County Voter Information Guide, CVIG) និងដែលមាននៅលើគេហទំព័រ ROV។ តម្រូវការបន្ថែមសម្រាប់ជំនួយផ្នែកភាសានឹងត្រូវពិចារណាតាមរយៈដំណើរការផ្តល់ធាតុចូលជាសាធារណៈ រួមទាំងធាតុចូលផ្តល់ឡើងដោយ LAAC របស់ខោនធីផងដែរ។

ROV នឹងខិតខំជ្រើសរើសយ៉ាងហោចណាស់មន្ត្រីបោះឆ្នោតម្នាក់និយាយភាសាអេស្ប៉ាញសម្រាប់មណ្ឌលបោះឆ្នោតនីមួយៗ ដើម្បីផ្តល់ជំនួយផ្នែកភាសា។ ប្រសិនបើមណ្ឌលបោះឆ្នោតស្ថិតនៅក្នុង ឬជាប់នឹងតំបន់ដែលមានតម្រូវការភាសាវៀតណាម តាហ្គាឡុក ឬ ខ្មែរនោះ ROV នឹងប្រឹងប្រែងឲ្យអស់លទ្ធភាព ដើម្បីជ្រើសរើសមន្ត្រីបោះឆ្នោតដែលចេះភាសានោះស្ទាត់ជំនាញ។ ROV ក៏នឹងផ្តល់សេវាអ្នកបកប្រែតាមទូរសព្ទផងដែរ តាមរយៈលេខារដ្ឋកាលីហ្វ័រញ៉ា ដែលមន្ត្រីបោះឆ្នោតអាចប្រើប្រាស់ ដើម្បីហៅចូលនិងនិយាយផ្ទាល់ជាមួយនឹងអ្នកបកប្រែដើម្បីជួយក្នុងការទំនាក់ទំនងជាមួយអ្នកបោះឆ្នោតជាភាសាផ្សេងៗទៀតផងដែរ។ ឧបករណ៍គូសសន្លឹកឆ្នោតដែលអាចប្រើប្រាស់បាន មានផ្ទុកតែខ្លឹមសារសន្លឹកឆ្នោត និងសម្លេងជាភាសាអង់គ្លេស។

## B. អ្នកបោះឆ្នោតដែលមានពិការភាព

ROV ប្តេជ្ញាចិត្តធ្វើការជាមួយនឹងអ្នកបោះឆ្នោតដែលមានពិការភាព ដើម្បីបង្កើននូវលទ្ធភាពចូលរួមក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ។ គេហទំព័រ ROV ផ្តល់នូវព័ត៌មានទូទៅអំពីកិច្ចខិតខំប្រឹងប្រែងទាំងនេះ និងធនធានទាំងឡាយដែលផ្តល់ដល់អ្នកបោះឆ្នោតដែលមានពិការភាព រួមទាំងប្រព័ន្ធចូលរួមបោះឆ្នោតពីចម្ងាយតាមសំបុត្រ សេវាពិការភាពដែលមាននៅតាមមណ្ឌលបោះឆ្នោត និងមានផ្តល់ជូននូវឯកសារបោះឆ្នោតតាមទម្រង់ជាជម្រើស។ អ្នកបោះឆ្នោតត្រូវបានលើកទឹកចិត្តឲ្យទាក់ទងមកកាន់ ROV ជាមួយនឹងសំណើជាក់លាក់សម្រាប់ជំនួយដោយការផ្ញើអ៊ីម៉ែលមកកាន់ rov-info@sonoma-county.org ។ បញ្ជីដ៏ពេញលេញនៃជម្រើសបោះឆ្នោតដែលអាចទទួលបាន និងជំនួយ ត្រូវបានដាក់នៅលើ គេហទំព័រ ROV។ ខោនធីក៏ផ្តល់នូវមគ្គុទ្ទេសក៍ព័ត៌មានអ្នកបោះឆ្នោតតាមអ៊ីនធឺណិតដែលអាចចូលប្រើបាន ដែលរួមមានសន្លឹកឆ្នោតយោងដែលអ្នកបោះឆ្នោតជាជនពិការអាចចូលទៅពិនិត្យ និងបោះពុម្ពសន្លឹកឆ្នោតគំរូរបស់ពួកគេ។

1. *គណៈកម្មការប្រឹក្សាលទ្ធភាពចូលរួមបោះឆ្នោត*

   ROV នឹងបង្កើតឡើងនូវគណៈកម្មការ VAAC ជាគណៈកម្មការប្រជាពលរដ្ឋ ដើម្បីផ្តល់អនុសាសន៍នានាសម្រាប់ធ្វើការលើកកម្ពស់ការចូលរួមបោះឆ្នោតនិងការទទួលបានឯកសារបោះឆ្នោត ខណៈពេលកំពុងកំណត់និងលុបបំបាត់ឧបសគ្គនានា។ VAAC ត្រូវបានបង្កើតឡើងដើម្បីផ្តល់ប្រឹក្សា និងជួយក្នុងការធានាដល់អ្នកបោះឆ្នោតទាំងអស់នៅក្នុងខោនធី Sonoma ឲ្យអាចបោះឆ្នោតបានដោយឯករាជ្យនិងដោយមានឯកជនភាព។ ROV នឹងធ្វើការជាមួយនឹងសមាជិក VAAC និងសហគមន៍ដៃគូ ដើម្បីផ្តល់ព័ត៌មាននិងជំរើសបោះឆ្នោតនានាដែលជាជម្រើសដល់អ្នកបោះឆ្នោតដែលមានពិការភាព។

2. *សិក្ខាសាលាអប់រំ*

សិក្ខាសាលានឹងរៀបចំឲ្យមានការបង្ហាញពីជម្រើសបោះឆ្នោតដែលអាចចូលរួមបានរបស់ ROV រួមទាំងប្រព័ន្ធចូលរួមបោះឆ្នោតពីចម្ងាយតាមសំបុត្រ (RAVBM) និងឧបករណ៍គូសសន្លឹកឆ្នោតដែលអាចប្រើប្រាស់នៅតាមមណ្ឌលបោះឆ្នោត (Dominion's ICX)។ សិក្ខាសាលានឹងកំណត់កាលវិភាគទៅតាមភាពចាំបាច់។ ការផ្សព្វផ្សាយពាណិជ្ជកម្មពីសិក្ខាសាលាទាំងនេះ នឹងត្រូវធ្វើឡើងនៅលើប្រព័ន្ធទំនាក់ទំនងសង្គម ដោយមានជំនួយពីការិយាល័យក្រុមការងារទំនាក់ទំនងរបស់រដ្ឋបាលខោនធី និងតាមរយៈសហគមន៍ដៃគូដែលជឿជាក់។ នៅតាមសិក្ខាសាលាទាំងនេះ ROV នឹងផ្ដល់នូវ៖

- ចូលរួមបោះឆ្នោតពីចម្ងាយតាមកម្មវិធីសំបុត្រ (សម្រាប់ដំណភ្ជាប់ត្រូវផ្ញើតាមអ៊ីម៉ែលទៅកាន់អ្នកបោះឆ្នោត)
- ការបង្ហាញពីផ្ទាំង RAVBM និងសម្លេង
- ការបង្ហាញពីឧបករណ៍គូសសន្លឹកឆ្នោត ICX ដោយមានសន្លឹកឆ្នោតគំរូ
- ការពិភាក្សាពីលទ្ធភាពទទួលបាននៃឯកសារតាមទម្រង់ជ្រើសរើស (បោះពុម្ពជាអក្សរធំៗ រង្វាស់សម្លេង គោលការណ៍ណែនាំពីព័ត៌មានសម្រាប់អ្នកបោះឆ្នោតខោនដែលអាចចូលរួមបាន និងលទ្ធភាពទទួលបានទម្រង់តាមជម្រើសសម្រាប់ឯកសារបោះឆ្នោតថ្នាក់រដ្ឋ។

3. *ប្រព័ន្ធផ្សព្វផ្សាយ/ការផ្សាយពាណិជ្ជកម្ម*

សេចក្ដីប្រកាសព័ត៌មាននឹងត្រូវបែងចែកនៅទូទាំងខោនធី Sonoma នឹងជូនដំណឹងពីប្រព័ន្ធទូរសព្ទជំនួយដល់អ្នកបោះឆ្នោតដោយឥតគិតថ្លៃ ដែលផ្ដល់ជំនួយជាភាសាអង់គ្លេស ដែលអាចភ្ជាប់អ្នកបោះឆ្នោតដែលមានពិការភាពជាមួយនឹង TTY (ទូរសព្ទជាអក្សរ) ធ្វើការអនុញ្ញាតដល់អ្នកបោះឆ្នោតដែលមានថ្លង់ ពិបាកស្ដាប់ ឬបញ្ហានិយាយ ដើម្បីប្រើទូរសព្ទទំនាក់ទំនងជាមួយនឹងបុគ្គលិក ROV។ សេចក្ដីប្រកាសព័ត៌មាននាពេលអនាគត នឹងបញ្ជាក់ថា ប្រព័ន្ធទូរសព្ទផ្ដល់ជំនួយដល់អ្នកបោះឆ្នោតមានសមត្ថភាព TTY។

*បណ្ដាញផ្សព្វផ្សាយជាឯកសារបោះពុម្ពសំខាន់ៗនិងតាមអនឡាញ ដូចជា Sonoma Media Investments (គ្របដណ្ដប់លើប្រព័ន្ធកម្មវិធីជាឯកសារបោះពុម្ពសំខាន់ៗនិងតាមអនឡាញនៅក្នុងខោនធីទាំងមូល មានដូចជា Press Democrat), Kenwood Press, Bodega Bay Navigator, Bay Area News Group, Sonoma West Times*

*ព្រមទាំងស្ថានីយវិទ្យុដែលគ្របដណ្តប់ទៅខោនធីនេះ រួមមាន Amaturo Sonoma Media Group, Sonoma Valley Commuinications និង Redwood Empire Sterocasters ជាដើម នឹងត្រូវបានប្រើប្រាស់ឲ្យបានច្រើនតាមដែលអាចធ្វើបានសម្រាប់ការចែកចាយសម្រាប់សេចក្តីប្រកាសព័ត៌មាននេះ។ ខោនធី Sonoma មិនមានបណ្តាញផ្សព្វផ្សាយព័ត៌មានតាមទូរទស្សន៍ TV ជាក់លាក់នោះទេ ប៉ុន្តែនឹងផ្តល់ជូននូវសេចក្តីប្រកាសព័ត៌មានទៅកាន់បណ្តាញប្រព័ន្ធផ្សព្វផ្សាយតាមទូរទស្សន៍ដែលក្រុមការងារទំនាក់ទំនងប្រចាំខោនធីសហការជាធម្មតា រួមមាន ABC7, KGO, KPIX, KRON, KSRO, KSVY និង KTVU។*

ឯកសារបោះពុម្ព ដូចជាប័ណ្ណប្រៃសណីយ៍ផ្ទាល់លើកទីពីរ នឹងណែនាំដល់អ្នកបោះឆ្នោតពីជម្រើសសន្លឹកឆ្នោតដែលអាចបោះបាន។

ROV អាចប្រើជំនួយ និងអនុសាសន៍ពីមធ្យោបាយប្រសើរបំផុត ដើម្បីទាក់ទងទៅកាន់អ្នកបោះឆ្នោតដែលមានពិការភាព។ សូមអ៊ីម៉ែលទៅកាន់ rov-info@sonoma-county.org នូវគំនិតសម្រាប់ផ្សព្វផ្សាយនានា។

4. *ឯកសារតាមទម្រង់ជ្រើសរើស*
   អ្នកបោះឆ្នោតដែលមានពិការភាពមានជម្រើសចូលរួមការបោះឆ្នោតមួយចំនួន។ ROV រៀបចំគោលការណ៍ព័ត៌មានសម្រាប់អ្នកបោះឆ្នោតតាមខោនធី (CVIG) សម្រាប់ការបោះឆ្នោតនីមួយៗ ដែលមានផ្ទុកនូវព័ត៌មានអំពីដំណើរការបោះឆ្នោតតាមសំបុត្រ ព្រមទាំងសេចក្តីណែនាំទាំងឡាយសម្រាប់ការប្រើប្រាស់ប្រព័ន្ធ RAVBM។ CVIG មានផ្តល់ជូនជាការបោះពុម្ពអក្សរធំៗ, PDF តាមអនឡាញ និងជម្រើសដែលអាចចូលប្រើបានជាអេក្រង់អាន ដោយប្រើឧបករណ៍រកមើលអ្នកបោះឆ្នោតរបស់ ROV ដែលរួមបញ្ចូលលទ្ធភាពចូលប្រើសន្លឹកឆ្នោតយោង។ វិធានការបានដាក់ចេញតាមទម្រង់ដែលអាចចូលរួមបានដោយអេក្រង់អាន។ CVIG បោះពុម្ពពង្រីកធំ និងវិធានការសម្លេងនានា អាចត្រូវបានស្នើសុំដោយអ៊ីម៉ែលទៅកាន់ rov-info@sonoma-county.org ០ឬហៅទូរសព្ទទៅកាន់ ROV តាមលេខ (707) 565-6800។

បញ្ជីពេញលេញនៃរបៀបចូលទៅប្រើប្រាស់ព័ត៌មានតាមទម្រង់ដែលជ្រើសរើសត្រូវបានដាក់នៅលើគេហទំព័រROV។

5. *ចូលរួមបោះឆ្នោតពីចម្ងាយតាមសំបុត្រ (RAVBM)*

ខោនធីទាំងអស់តម្រូវឲ្យផ្តល់ជម្រើសចូលរួមបោះឆ្នោតពីចម្ងាយតាមសំបុត្រសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាព។ ប្រព័ន្ធនេះ អនុញ្ញាតឲ្យអ្នកបោះឆ្នោតចូលទៅកាន់សន្លឹកឆ្នោតត្រឹមត្រូវរបស់គេតាមអនឡាញ និងគូសជម្រើសទាំងឡាយដោយប្រើប្រាស់បច្ចេកវិទ្យាជំនួយដោយផ្ទាល់ខ្លួនគេ។ នៅពេលដែលជម្រើសលើសន្លឹកឆ្នោតត្រូវបានគូសភ្លាម អ្នកបោះឆ្នោតត្រូវបានតម្រូវឲ្យបោះពុម្ពវាចេញនូវការជ្រើសរើសនិងផ្ញើវាត្រឡប់មកវិញតាមសំបុត្រ ឬ ដាក់តាមហិបទម្លាក់សន្លឹកឆ្នោតនៅមណ្ឌលបោះឆ្នោត ឬ នៅការិយាល័យ ROV។ ព័ត៌មានទាក់ទងនឹងដំណើរការ RAVBM មានផ្តល់ជូននៅលើគេហទំព័រROV។

អ្នកបោះឆ្នោតដែលមានពិការភាពអាចស្នើសុំ បោះឆ្នោតដោយផ្ញើសន្លឹកឆ្នោតតាមសំបុត្រតាមទម្រង់ដែលអាចបោះបាន ដោយផ្ញើត្រឡប់នូវពាក្យសុំដែលមានបង់ថ្លៃផ្ញើរួចជាស្រេចនៅផ្នែកខាងក្រោយនៃសៀវភៅណែនាំព័ត៌មានបោះឆ្នោតខោនធី។

អ្នកបោះឆ្នោតដែលជ្រើសរើសប្រើប្រព័ន្ធនេះ ត្រូវតែបញ្ជាក់ថាពួកគេមានពិការភាព ត្រូវតែមានភ្ជាប់អ៊ីនធឺណិត និងត្រូវតែមានម៉ាស៊ីនព្រីន ដើម្បីបោះពុម្ពចេញនូវសន្លឹកឆ្នោតជ្រើសរើសរបស់គេ។ ដោយហេតុថា អ្នកបោះឆ្នោតទាំងអស់ទទួលបានសន្លឹកឆ្នោតតាមសំបុត្រនោះ អ្នកបោះឆ្នោតប្រើប្រាស់ប្រព័ន្ធ RAVBM អាចនឹងប្រើស្រោមសំបុត្រពណ៌ខៀវ ដែលពួកគេទទួលបានតាមសំបុត្រ ដើម្បីផ្ញើត្រឡប់សន្លឹកឆ្នោតមកវិញនោះ ពួកគេក៏អាចទម្រង់ស្រោមសំបុត្រចេញពីប្រព័ន្ធ RAVBM បានផងដែរ ឬ ពួកគេអាចមកទទួលស្រោមសំបុត្រជំនួសថ្មីនៅតាមមណ្ឌលបោះឆ្នោតណាមួយក៏បាន ឬនៅឯការិយាល័យ ROV ផ្ទាល់។ ស្រោមសំបុត្រពណ៌ខៀវត្រូវបានផ្ញើទៅគ្រប់អ្នកបោះឆ្នោតទាំងអស់ដែលមានចន្លោះទំនេរក្រោមផ្នត់គ្របស្រោមសំបុត្រ ដែលជាកន្លែងអ្នកបោះឆ្នោតគួរចុះហត្ថលេខា។

ស្រោមសំបុត្រទាំងអស់ត្រូវបានចុះហត្ថលេខាដោយគូសកំនត់ដោយអ្នកបោះឆ្នោតមុននឹងសន្លឹកឆ្នោតត្រូវបានរាប់។ ប្រសិនបើស្រោមសំបុត្រមិនត្រូវបានចុះហត្ថលេខា ឬប្រសិនបើហត្ថលេខាមិនត្រូវទៅតាមអ្វីដែលមាននៅលើឯកសារអ្នកបោះឆ្នោតទេនោះ ROV នឹងផ្ញើសំបុត្រទៅអ្នកបោះឆ្នោតដោយមានសេចក្តីណែនាំនិងកាលបរិច្ឆេទកំណត់សម្រាប់ការជួសជុលស្ថានការ។

ដើម្បីផ្ទៀងផ្ទាត់ថា ROV បានទទួលសន្លឹកឆ្នោតនោះ អ្នកបោះឆ្នោតអាចចូលមើលនៅលើគេហទំព័រលេខារដ្ឋកាលីហ្វ័រញ៉ា និងចុចលើ ស្ថានភាពអ្នកបោះឆ្នោតរបស់ខ្ញុំ

6. *លទ្ធភាពចូលទៅកានមណ្ឌលបោះឆ្នោត*

មណ្ឌលបោះឆ្នោតនិងទីតាំងហិបទម្លាក់សន្លឹកឆ្នោត ត្រូវបានជ្រើសរើសដោយការប្រើប្រាស់គោលការណ៍ ADA ចេញពីបញ្ជីជ្រើសរើសលទ្ធភាពទីតាំងបោះឆ្នោត។ បញ្ជីជ្រើសរើសទាំងនេះត្រូវបានប្រើដើម្បីកំណត់ពីទីតាំងដែលអាចចូលបាន។ ប្រសិនបើរកឃើញថាមានឧបសគ្គរារាំងការចូលរបស់បុគ្គលទៅក្នុងមណ្ឌលបោះឆ្នោត ឬ ការប្រើប្រាស់ហិបទម្លាក់សន្លឹកឆ្នោតនោះ ROV នឹងធ្វើការផ្លាស់ប្តូរនៅចំថ្ងៃ ឬមុនថ្ងៃបោះឆ្នោត ដោយប្រើប្រាស់បរិក្ខារនិងសញ្ញាបន្ថែម។ រាល់សំណួរទាក់ទងនឹងការចូលជារូបវន្តទៅកាន់មណ្ឌលបោះឆ្នោត ឬ ទីតាំងហិបទម្លាក់សន្លឹកឆ្នោតនោះ អាចបញ្ជូនផ្ទាល់មកកាន់ការិយាល័យ ROV ដោយអ៊ីម៉ែលមកកាន់ rov-info@sonoma-county.org ឬហៅទូរសព្ទមកលេខ (707) 565-6800។

មណ្ឌលបោះឆ្នោតទាំងអស់ នឹងមានយ៉ាងហោចណាស់បន្ទប់បោះឆ្នោតពីរដែលអាចចូលបានសម្រាប់កៅអី ឬរទេះជនពិការ កែវពង្រីក និងប៊ិចគាប។ នឹងមានយ៉ាងហោចណាស់ឧបករណ៍គូសសន្លឹកឆ្នោតដែលអាចប្រើបានបី ដែលអាចដាក់កៅអី ឬចូលរទេះជនពិការបាន។ នៅតាមមណ្ឌលបោះឆ្នោត រាល់អ្នកបោះឆ្នោតអាចប្រើប្រាស់ឧបករណ៍គូសសន្លឹកឆ្នោតទាំងនេះបានដើម្បីគូសលើសន្លឹកឆ្នោតរបស់ខ្លួនបានដោយឯករាជ្យនិងដោយមានឯកជនភាព។ ក្រោយពីការជួបពិនិត្យជាមួយនឹងមន្ត្រីបោះឆ្នោតរួចមក អ្នកបោះឆ្នោតទាំងឡាយត្រូវបានផ្តល់នូវប័ណ្ណចូលបោះឆ្នោតមួយ ដែលមានទំនាក់ទំនងនឹងឧបករណ៍អាចចូលបានជាមួយនឹងសន្លឹកឆ្នោតរបស់គេ។ សន្លឹកឆ្នោតអាចត្រូវបានគូសដោយប្រើប្រាស់ការស្ទាបលើអេក្រង់បង្ហាញ ឧបករណ៍ជាសម្លេងដែលបានផ្តល់ជូនដោយមានអក្សរសម្រាប់ជនពិការភ្នែក ឬ បច្ចេកវិទ្យាជំនួយផ្ទាល់ខ្លួនរបស់គេ។ មុខងារសំខាន់ៗទាំងឡាយរួមមាន៖

- ថេប្លេតចុចលើអេក្រង់ ដោយមានជម្រើសប្តូទំហំអក្សរ និងពន្លឺនៅលើថាប្លេត។
- សម្ព័ន្ធទំនាក់ទំនងដែលភ្ជាប់ដោយសម្លេង (Audio Tactile Interface, ATI) ដោយមានអក្សរសម្រាប់ជនពិការភ្នែក
- កាសត្រចៀកនិងសេចក្តីណែនាំជាសម្លេងជាភាសាអង់គ្លេស
- ម៉ាសឯកជនភាព សម្រាប់អ្នកបោះឆ្នោតដែលពិបាកមើល ដើម្បីធានាថាការបោះឆ្នោតរបស់គេត្រូវបានរក្សាឯកជនភាព ដោយសារតែគេប្រើការណែនាំជាសម្លេង។
- សមត្ថភាពសម្រាប់អ្នកបោះឆ្នោតដើម្បីប្រើប្រាស់នូវឧបករណ៍ជំនួយបញ្ជូនសញ្ញាតាមដង្ហើមចេញចូល

ម៉ាស៊ីននេះមិនសរុបឬរាប់សម្លេងឆ្នោតទេ។ ក្រោយបញ្ចប់ការគូសលើសន្លឹកឆ្នោតរបស់ខ្លួនភ្លាម អ្នកបោះឆ្នោតត្រូវបោះពុម្ពចេញនូវការជ្រើសរើសរបស់គេ ហើយដាក់សន្លឹកឆ្នោតដែលបានបោះពុម្ពនោះចូលទៅក្នុងហិបសន្លឹកឆ្នោត។ ពុំមានព័ត៌មានអ្នកបោះឆ្នោតត្រូវបានរក្សាទុកនៅលើឧបករណ៍គូសសន្លឹកឆ្នោតនោះទេ ធានាថាសន្លឹកឆ្នោតទាំងអស់ត្រូវបានរក្សាទុកដោយសម្ងាត់និងមានឯកជនភាព។

អ្នកបោះឆ្នោតណាដែលមិនពានចូលទៅកាន់មណ្ឌលបោះឆ្នោតដោយផ្ទាល់បាន មានជម្រើសស្នើសុំការបោះឆ្នោតដោយឲ្យមានការយកសន្លឹកឆ្នោតមកឲ្យ។ អ្នកបោះឆ្នោតអាចហៅទៅកាន់មណ្ឌលបោះឆ្នោតតាមលេខនៅលើប្រអប់ហៅទូរសព្ទនៅតាមមណ្ឌលសន្លឹកឆ្នោត ឬ ឲ្យមានអ្នករត់សំបុត្រ ឬ មិត្តភក្តិចូលទៅកាន់មណ្ឌលបោះឆ្នោត និងស្នើសុំក៏បាន។ បុគ្គលិកមណ្ឌលបោះឆ្នោតនឹងយកសន្លឹកឆ្នោតជំនួសថ្មីទៅកាន់រថយន្តរបសគេ។ ដើម្បីស្នើសុំការបោះឆ្នោតដោយយកសន្លឹកឆ្នោតទៅឲ្យនៅតាមការិយាល័យ ROV អ្នកបោះឆ្នោតអាចទាក់ទងមក ROV តាម rov-info@sonoma-county.org ឬដោយហៅទូរសព្ទមកលេខ (707) 565-6800។ ការិយាល័យ ROV ស្ថិតនៅ 435 Fiscal Drive ក្នុង Santa Rosa នឹងមានឧបករណ៍គូសសន្លឹកឆ្នោតផ្តល់ជូន សម្រាប់ប្រើប្រាស់ចាប់ផ្តើមក្នុងរយៈពេល 29 ថ្ងៃមិនថ្ងៃបោះឆ្នោត ព្រមទាំងជម្រើសស្នើសុំការបោះឆ្នោតដោយតម្រូវឲ្យយកសន្លឹកឆ្នោតមកឲ្យបានផងដែរ។

7. *ជម្រើសមកទទួលយកសន្លឹកឆ្នោត*
រាល់អ្នកបោះឆ្នោតនៅខោនធី Sonoma ដែលបានចុះឈ្មោះ នឹងត្រូវបានផ្ញើ សន្លឹកឆ្នោតតាមប៉ុស្តិ៍ (VBM) កុំអោយយឺតជាង 29 ថ្ងៃមុនថ្ងៃបោះឆ្នោត។ រាល់អ្នកបោះឆ្នោតអាចស្នើសុំសន្លឹកឆ្នោតជំនួសថ្មីបានដោយទូរសព្ទមកកាន់លេខ (707) 565-6800 ឬ (800) 750-8683, ដោយផ្ញើអ៊ីម៉ែលទៅកាន់ rov-absentee@sonoma-county.org, ដោយការផ្ញើទូរសារទៅលេខ (707) 565-6843, ដោយមកផ្ទាល់នៅតាមមណ្ឌលបោះឆ្នោត ឬ នៅការិយាល័យ ROV។

ប្រសិនបើអ្នកបោះឆ្នោតមិនទទួលបានសន្លឹកកញ្ចប់បោះឆ្នោតតាមសំបុត្ររបស់គេទេ ពួកគេអាចទូរសព្ទមកកាន់ការិយាល័យតាមលេខ (707) 565-6800 សម្រាប់ការប្តូរកញ្ចប់ថ្មី សូមមកកាន់ការិយាល័យ ROV ឬ មណ្ឌលបោះឆ្នោតណាមួយនៅពេលបើកដំណើរការ។ កញ្ចប់បោះឆ្នោតតាមសំបុត្ររបស់អ្នកបោះឆ្នោត អាចមកទទួលយកបានដោយមិត្តភក្តិ ឬ សាច់

ញាតិ ប្រសិនបើអ្នកបោះឆ្នោតបំពេញទម្រង់អនុញ្ញាតបន្ទាន់សម្រាប់ការមកទទួលសន្លឹកឆ្នោតដែលមានផ្តល់ជូននៅលើ គេហទព័ររបស់លេខាធិការដ្ឋានកាលីហ្វ័រញ៉ា។

8. *ការបោះឆ្នោតបន្ទាន់តាមសន្លឹកឆ្នោតផ្ញើតាមប៉ុស្តិ៍*

ប្រសិនបើក្នុងរយៈពេល 7 ថ្ងៃចុងក្រោយមុនថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតយល់ថា ពួកគេមិនអាចទៅបោះឆ្នោតដោយខ្លួនឯងបាន ដោយសារជំងឺ ឬពិការភាពដែលបណ្តាលមកពីពេលឆ្លងទន្លេនៅមន្ទីរពេទ្យ ឬមណ្ឌលថែទាំ ឬបើអ្នកបោះឆ្នោតត្រូវដេកព្យាបាលជំងឺនៅផ្ទះរបស់ពួកគេ ឬបើមិនដូច្នេះទេអវត្តមានក្នុងមណ្ឌលបោះឆ្នោតរបស់ពួកគេនៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតអាចស្នើសុំការបោះឆ្នោតបន្ទាន់តាមរយៈសន្លឹកឆ្នោតផ្ញើតាមប៉ុស្តិ៍។ អ្នកបោះឆ្នោតត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរ ដែលបានចុះហត្ថលេខាក្រោមការផាកពិន័យពីការបំពានសម្បថ ផ្តល់សិទ្ធិឱ្យអ្នកតំណាងឱ្យយកសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោត ហើយប្រគល់សន្លឹកឆ្នោតទៅឱ្យអ្នកបោះឆ្នោតវិញ។ អ្នកតំណាងពេញសិទ្ធិរបស់អ្នកបោះឆ្នោតនឹងទទួលបានសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតបន្ទាប់ពីបង្ហាញសេចក្តីថ្លែងការណ៍ដែលបានចុះហត្ថលេខាទៅកាន់ការិយាល័យចុះឈ្មោះបោះឆ្នោតនៅខោនធី Sonoma ដែលមានអាសយដ្ឋាននៅ 435 Fiscal Drive ក្នុងទីក្រុងសាន់តារ៉ូសា ក្នុងអំឡុងពេលម៉ោងធ្វើការធម្មតាពីម៉ោង 8 ព្រឹកដល់ម៉ោង 5 ល្ងាច ម៉ោងនៅប៉ាស៊ីហ្វិក។

អ្នកបោះឆ្នោតត្រូវគូសសន្លឹកឆ្នោត ហើយដាក់វានៅក្នុងស្រោមសំបុត្រអោយបានត្រឹមត្រូវ បំពេញ និងចុះហត្ថលេខាលើស្រោមសំបុត្រ ហើយប្រគល់សន្លឹកឆ្នោតដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងពេញសិទ្ធិ ទៅកាន់ការិយាល័យចុះឈ្មោះបោះឆ្នោត ឬទៅកន្លែងបោះឆ្នោត ឬមណ្ឌលបោះឆ្នោតណាមួយនៅក្នុងខោនធី Sonoma មុនពេលការបិទការបោះឆ្នោត។

អ្នកបោះឆ្នោតដែលមានសំណួរអំពីការបោះឆ្នោតបន្ទាន់តាមសន្លឹកឆ្នោតផ្ញើតាមប៉ុស្តិ៍ អាចទាក់ទងការិយាល័យរបស់យើងតាមរយៈលេខ (707) 565-6800, ឬអ៊ីម៉ែល rov-absentee@sonoma-county.org។

## IV. ការឆ្លើយតបការផកល្វែងក្នុងការចូលរួម

វាជាគោលបំណងរបស់ ROV និងខោនធី Sonoma ត្រូវធានាឲ្យមានការចូលរួមស្មើគ្នាចំពោះហិបសន្លឹកឆ្នោតសម្រាប់ពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតទាំងអស់ ដូចបានកំណត់ដោយច្បាប់។ ROV ប្រឹងប្រែងឲ្យអសើពីលទ្ធភាពដើម្បីចូលរួមព្រឹត្តិការណ៍នានា ផ្តល់នូវបទបង្ហាញទាំងឡាយ និងផ្តល់នូ

វព័ត៌មានតាមតំបន់ទាំងឡាយដែលមានការចូលរួមបោះឆ្នោតតិចនោះ ទៅតាមការស្នើសុំ។ ROV នឹងផ្តល់នូវព័ត៌មានបោះឆ្នោតទៅតាមផ្ទះផ្តល់ការថែទាំ មន្ទីរពេទ្យ និងនាយកដ្ឋានសុខភាពផ្លូវចិត្តខោនធី Sonoma នាយកដ្ឋានរបស់ប៉ូលីសខោនធី Sonoma ការិយាល័យយោធានិងការិយាល័យធ្វើលិខិតឆ្លងដែនទាំងឡាយ។ ឯកសារនឹងត្រូវផ្ញើទៅតាមអ៊ីម៉ែល ហើយនឹងរួមបញ្ចូលនូវព័ត៌មានអំពីរបៀបស្នើសុំទម្រង់ចុះឈ្មោះអ្នកបោះឆ្នោត និងព័ត៌មានផ្សេងៗទៀត ដំណភ្ជាប់ទៅកាន់គេហទំព័ររបស់យើងដើម្បីមើលនូវ ផែនការគ្រប់គ្រងការបោះឆ្នោត (Election Administration Plan, EAP) របស់យើង និងព័ត៌មានទំនាក់ទំនងរបស់យើង ប្រសិនបើពួគេ ឬ អតិថិជនរបស់គេមានសំណួរនានានោះ។

## A. ការចុះឈ្មោះបោះឆ្នោត

ពលរដ្ឋខោនធី Sonoma ដែលមានសិទ្ធិ អាចចុះឈ្មោះបោះឆ្នោតតាមអនឡាញដោយផ្ទាល់នៅលើគេហទំព័រលេខារដ្ឋ៖ https://registertovote.ca.gov/ ឬចូលទៅកាន់គេហទំព័រចុះឈ្មោះអ្នកបោះឆ្នោតរដ្ឋតាមរយៈដំណភ្ជាប់ចេញពី គេហទំព័រ ROV។ ពលរដ្ឋទាំងឡាយក៏អាចមកទទួលយកទម្រង់ចុះឈ្មោះអ្នកបោះឆ្នោតនៅការិយាល័យ ROV, សាលាក្រុង, បណ្ណាល័យ, ប៉ុស្តិ៍ប្រៃសណីយ៍ និងការិយាល័យរដ្ឋាភិបាលភាគច្រើននៅទូទាំងខោនធី។ ទីភ្នាក់ងារខោនធី Sonoma ដែលផ្តល់សេវាកម្មជូនគ្រួសារមានចំណូលទាប និងបុគ្គលមានពីការភាព ផ្តល់ទម្រង់ចុះឈ្មោះបោះឆ្នោតទៅដល់អតិថិជនរបស់ខ្លួន។ នាយកដ្ឋានយានយន្ត (Department of Motor Vehicles, DMV) និងលេខារដ្ឋ (Secretary of State, SOS) បានបង្កើតឡើលងនូវកម្មវិធីអ្នកបោះឆ្នោតតាមរយៈយានយន្តដូចដែលបានកំណត់ដោយ AB 1461។ ក្នុងអំឡុងប្រតិបត្តិការ DMV កម្មវិធីថ្មីនេះនឹងផ្តល់ដោយស្វ័យប្រវត្តិនូវការចុះឈ្មោះបុគ្គលណាម្នាក់ដែលមានសិទ្ធិបោះឆ្នោត លើកលែងតែបុគ្គលនោះបដិសេធមិនចុះឈ្មោះ។ ROV ក៏នឹងផ្ញើទម្រង់ចុះឈ្មោះទៅតាមការស្នើសុំផងដែរ។

ROV ផ្តល់នូវធនធានច្បាប់ចុះឈ្មោះអ្នកបោះឆ្នោត_ ក់ជាតិ (National Voter Registration Act, NVRA) និងការបណ្តុះបណ្តាលទៅដល់ទីភ្នាក់ងារខោនធីទាំងឡាយ ដែលផ្តល់សេវាកម្មដល់ពលរដ្ឋមានចំណូលទាប និងបុគ្គលមានពិការភាពទៅតាមការស្នើសុំ។ ROV នឹងផ្តល់នូវឯកសារ ព័ត៌មាន និងការបណ្តុះបណ្តាលបន្ថែមទៅតាមការស្នើសុំមកកាន់អ្នកសម្របសម្រួល និងបុគ្គលិកនៅតាមទីភ្នាក់ងារខោនធីទាំងឡាយ។

## B. ការប្រមូលទិន្នន័យ & ការពិនិត្យឡើងវិញ

ក្រោយពីការបោះឆ្នោតនីមួយៗដែលត្រូវបានធ្វើឡើងស្ថិតក្រោមច្បាប់ VCA នោះ ROV នឹងពិនិត្យឡើងវិញទៅលើមតិយោបល់ទាំងឡាយដែលទទួលបានពីអ្នកបោះឆ្នោត ហើយនឹងការស្នើសុំធាតុចូលពី

LAAC VAAC និងសហគមន៍ដៃគូស្តីពីទិន្នន័យដែលប្រមូលបានស្របទៅតាមក្រមបោះឆ្នោតកាលីហ្វ័រញ៉ា 4005។ ROV នឹងប្រឹងប្រែងឲ្យបានសមស្រប ដើម្បីឆ្លើយតបទៅនឹងភាពមិនស៊ីគ្នាទាំងធំៗងឡាយ ដែលត្រូវបានកំណត់ឡើងទៅតាមបញ្ហាម្តងមួយៗ។

ដើម្បីឆ្លើយតបទៅនឹងការធកល្វែងដែលកំណត់ឡើងនៅក្នុងការចូលរួមរបស់អ្នកបោះឆ្នោតនោះ ROV នឹងប្តេជ្ញាៈ

- ធ្វើការជ្រើសរើសនិងស្នង់មតិពីទីតាំងមានសក្តានុពលទាំងឡាយនៅក្នុងសហគមន៍ដែលអាចរៀបចំមណ្ឌលបោះឆ្នោតដែលចូលបាន។
- ជួបជាមួយទីភ្នាក់ងារទាំងឡាយដែលផ្តល់សេវាកម្មទៅដល់សហគមន៍ រួមបញ្ចូលដោយមិនកំណត់មាន Becoming Independent, Disability Services and Legal Center, Council on Aging, YM/YWCA ដើម្បីផ្តល់ពត៌មានអ្នកបោះឆ្នោត ទម្រង់ចុះឈ្មោះអ្នកបោះឆ្នោត និងខិត្តប័ណ្ណ/បដា សម្រាប់ការបោះឆ្នោតឆ្នាំ 2022។
- រៀបចំយុទ្ធនាការចុះឈ្មោះនៅមុនថ្ងៃបោះឆ្នោត

បន្ថែមលើនេះ ROV នឹងធ្វើការដើម្បីកំណត់តំបន់ខុសៗគ្នានៅក្នុងខោនធី Sonoma ដែលមានអ្នកចេញទៅបោះឆ្នោតទាបជាមធ្យមសម្រាប់ខោនធី។ ទិន្នន័យនេះនឹងត្រូវប្រើប្រាស់ដោយ ROV ដើម្បីបង្កើនកម្រិតផ្សព្វផ្សាយនៅតាមតំបន់ជាក់លាក់ ក៏ដូចជាបណ្តុំសហគមន៍ផ្សេងទៀត ដើម្បីជួយផ្សព្វផ្សាយនិងចែកចាយព័ត៌មានបោះឆ្នោត។

## V. ថវិកា

VCA តម្រូវឲ្យមានការអប់រំនិងផ្សព្វផ្សាយខ្លាំងក្លាអំពីដំណើរការគំរូមណ្ឌលបោះឆ្នោតថ្មី។ គោលបំណងរបស់ ROV គឺត្រូវបង្កើនការចុះឈ្មោះអ្នកបោះឆ្នោត ការចូលរួម និងការចេញទៅបោះឆ្នោត។

ROV ផ្តល់ណុវការគាំទ្រខាងក្នុងសម្រាប់ការរៀបចំឯកសារផ្សព្វផ្សាយ បទបង្ហាញជាសាធារណៈ និងព្រឹត្តិការណ៍ផ្សព្វផ្សាយតាមសហគមន៍នានា។ ថវិកាមិនរួមបញ្ចូលនូវការទិញម៉ោងផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ កាសែត និងប្រព័ន្ធទំនាក់ទំនងសង្គមទេនាពេលកន្លងមក ប៉ុន្តែនឹងចាំបាច់ដាក់បញ្ចូលសម្រាប់ការផ្សព្វផ្សាយទាក់ទងទៅនឹងការផ្ទេរទៅកាន់ VCA នោះ។ នឹងមានការចំណាយលើការបោះពុម្ព និងការផ្ញើសម្រាប់ការផ្ញើផ្ទាល់ទៅកាន់អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួច។

ព័ត៌មានពីថវិកាសម្រាប់ការអប់រំនិងផ្សព្វផ្សាយ អាចរកឃើញក្នុងឧបសម្ព័ន្ធ D។ ប្រសិនបើប្រាក់បន្ថែមត្រូវបានផ្តល់សម្រាប់ការអប់រំអ្នកបោះឆ្នោត និងកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយ។ ឧបសម្ព័ន្ធនឹងត្រូវធ្វើបច្ចុប្បន្នភាពដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរ ឬ ការបន្ថែមទាំងឡាយ។

ខោនធី Sonoma បានប្រើប្រាស់គំរូបោះឆ្នោតដូចគ្នាទៅនឹងច្បាប់ VCA ដែរ សម្រាប់ការបោះឆ្នោតប្រធានាធិបតីខែវិច្ឆិកា ឆ្នាំ2020 ដោសារតែច្បាប់ធ្វើបានត្រូវបានអនុម័តិឡើងដាក់លាក់ដល់ការបោះឆ្នោតនោះ។ ច្បាប់នេះបានអនុញ្ញាតឲ្យ ROV ប្រើប្រាស់កញ្ចប់ថវិកា ដើម្បីទិញម៉ាស៊ីនព្រីនសន្លឹកឆ្នោតចល័ត (Mobile Ballot Printers, MBP) រទេះដឹកជញ្ជូនម៉ាស៊ីនទាំងនោះ ម៉ាស៊ីនព្រីនស្លាកសម្រាប់ប្រើប្រាស់ក្នុងការបង្កើតឡើងនូវបញ្ជីឈ្មោះអ្នកបោះឆ្នោតរួមមួយជាស្រេច និងរ៉ោទ័រម៉ាក Cradlepoint ដែលផ្តាច់ចេញពីអ៊ីនធឺណិត ដើម្បីធានាដល់ការតភ្ជាប់ទៅកាន់មូលដ្ឋានទិន្នន័យអ្នកបោះឆ្នោតក្តោបទៅលើមណ្ឌលបោះឆ្នោតទាំង 30។ សម្រាប់អ្នកបោះឆ្នោតដែលចូលមក ឬឡែបថបបញ្ជីឈ្មោះនោះ ROV បានប្រើឡែបថបដែលបានទិញសម្រាប់ អ្នកវាយតម្លៃ DMP ដែលត្រូវផ្តល់ឲ្យយើងខ្ចីសម្រាប់ការបោះឆ្នោតខែវិច្ឆិកាឆ្នាំ2020។ ROV នឹងត្រូវការទិញនូវឡែបថបថ្មីពី 70-80 គ្រឿងសម្រាប់អ្នកបោះឆ្នោតចុះឈ្មោះចូលបន្តទៅមុខ ដែលនឹងត្រូវផ្តល់ផ្តាច់មុខទៅឲ្យ ROV។ ROV ក៏នឹងត្រូវការទិញបរិក្ខាសម្រាប់យ៉ាងហោចណាស់ក៏មណ្ឌលបោះឆ្នោតមួយដែរ ដោយសារតែការចុះឈ្មោះបានកើនឡើង និងបរិក្ខារបំរុង ដើម្បីធានាការជំនួសបរិក្ខារថ្មីអាចត្រូវបានដាក់ជូនតាមតម្រូវការក្នុងករណីដែលបរិក្ខារមិនដំណើរការក្នុងអំឡុងពេលបោះឆ្នោត។ ROV ប៉ាន់ប្រមាណ នឹងមិនមានការសន្សំចំណាយបានទេក្នុងការប្តូរទៅកាន់គំរូ VCA នោះ ដោយសារតែចំណាយដែលត្រូវបានប្រមើលទៅលើការផ្សព្វផ្សាយ ការផ្ញើតាមប្រៃសណីយ៍ ការគាំទ្រដល់មណ្ឌលបោះឆ្នោត និង ការធ្វើការថែមម៉ោងសម្រាប់និយោជិតបណ្តោះអាសន្នជំនួសឲ្យប្រាក់ឧបត្ថម្ភដល់បុគ្គលិកបោះឆ្នោត ជំនួយផ្នែក ពត៌មានវិទ្យា និងការភ្ជាប់បណ្តាញសម្រាប់មណ្ឌលបើឆ្នោត និងបុគ្គលិកបណ្តោះអាសន្នផ្តល់សេវានៅតាមហិបទម្លាក់សន្លឹកឆ្នោត។

## ផ្នែក 2៖ ផែនការរដ្ឋបាលបោះឆ្នោត

### I. ទិដ្ឋភាពទូទៅ

ច្បាប់ជម្រើសអ្នកបោះឆ្នោតរដ្ឋកាលីហ្វ័រញ៉ា (VCA) តម្រូវឲ្យខោនធីដាក់បញ្ជូនមកនូវផែនការរដ្ឋបាលបោះឆ្នោត (EAP) ទៅកាន់សាធារណជន ដែលនាំមកនូវរបៀបដែល ROV ខោនធី Sonoma នឹងគ្រប់គ្រងការបោះឆ្នោតស្ថិតក្រោមច្បាប់ VCA។

ខោនធី Sonoma អាចប្រើប្រាស់គំរូបោះឆ្នោតដូចគ្នាទៅនឹងគំរូកំណត់ដោយច្បាប់ VCA បាន សម្រាប់ការបោះឆ្នោតប្រធានាធិបតីខែវិច្ឆិកាឆ្នាំ 2020 និងមានការមកចូលរួមបោះឆ្នោតខ្ពស់បំផុតមិនធ្លាប់មាននៅក្នុងរដ្ឋ។ យើងអាចផ្តល់ដល់អ្នកបោះឆ្នោតនូវភាពងាយស្រួលនិងផ្តល់នូវសុវត្ថិភាពបោះឆ្នោតក្នុងអំឡុងជំងឺរាតត្បាតដោយការផ្ញើទៅឲ្យអ្នកបោះឆ្នោតម្នាក់ៗនូវសន្លឹកឆ្នោតដែលពួកគេមានជម្រើសប្រើប្រាស់ និងបញ្ចូលត្រឡប់មកវិញ ឬជំនួសឲ្យការបោះឆ្នោតដោយត្រូវមកផ្ទាល់ ក្នុងករណីវាជាការពេញចិត្តរបស់គេនោះ។ ជាជាងដែលត្រូវភ្ជាប់ទៅកាន់កន្លែងបោះឆ្នោតណាមួយជាក់លាក់នោះ គំរូដូចច្បាប់ VCA បានផ្តល់ដល់អ្នកបោះឆ្នោតនូវលទ្ធភាពដើម្បីជ្រើសរើសកន្លែងបោះឆ្នោតដែលមានភាពងាយស្រួលបំផុតដល់ពួកគេ និងក៏ត្រូវបានផ្តល់បន្ថែមនូវការបោះឆ្នោតមុនថ្ងៃបោះឆ្នោតថែមទៀត ដើម្បីធានាឲ្យមានឱកាសឲ្យបានច្រើនសម្រាប់អ្នកបោះឆ្នោតធ្វើការបោះឆ្នោត។ ការបោះឆ្នោតដោយមកផ្ទាល់នៅតែពេញនិយមនៅថ្ងៃបោះឆ្នោតនៅទូទាំងខោនធី ដែលមាន 30 មណ្ឌលបោះឆ្នោតមានបុគ្គលិកច្រើនគ្រប់គ្រាន់ជួយដល់អ្នកបោះឆ្នោត និងធានាបាននូវបទពិសោធន៍បោះឆ្នោតដោយសុវត្ថិភាព មានទីតាំងមួយចំនួនតូចមានការតម្រង់ជួរ ឬការពន្យាពេលយូរនៅថ្ងៃបោះឆ្នោត។ ការិយាល័យសំខាន់របស់ ROV បានប្រើប្រាស់នូវប្រព័ន្ធ QLess ដើម្បីអនុញ្ញាតឲ្យអ្នកបោះឆ្នោត "តម្រង់ជួរ" ជាអេឡិចត្រូនិក និងអនុញ្ញាតឲ្យពួកគេរង់ចាំនៅក្នុងរថយន្តរបស់គេរហូតដល់លេខរបស់គេត្រូវបានហៅ ហើយពួកគេបានចេញមកចូលក្នុងការិយាល័យ ROV ដើមសុំជំនួយ។ ធ្វើបែបនេះ បានអនុញ្ញាតឲ្យមានការបោះឆ្នោតដោយសុវត្ថិភាព និងធានាបាននូវគម្លាតសង្គមសម្រាប់អ្នកទាំងនោះដែលកំពុងរង់ចាំសុំជំនួយនោះ។ ROV កំពុងតែបន្តធ្វើការកែលម្អចំពោះដំណើរការចំនួនច្រើននៃសម្លេងឆ្នោតដែលបានបញ្ជូនត្រឡប់មកតាមសំបុត្រ និងចំពោះបទពិសោធន៍បោះឆ្នោតដោយមកផ្ទាល់។

ផែនការនេះនឹងដាក់ចេញនូវព្រឹត្តិការណ៍នានាដែលកើតឡើង ដើម្បីគ្រប់គ្រងការបោះឆ្នោតស្ថិតក្រោមច្បាប់ VCA។

សំណួរ ឬ ការព្រួយបារម្ភនានា

ការិយាល័យកណ្តាល ROV លេខ (707) 565-6800
ប្រព័ន្ធទូរសព្ទឥតគិតថ្លៃលេខ (800) 750-8683
Rov-info@sonoma-county.org

## II. <u>សកម្មភាពមុនការបោះឆ្នោត</u>

### A. ការពិនិត្យមើលឡើងវិញទៅលើការបោះឆ្នោតឆ្នាំ 2020

វិធីសាស្ត្រប្រមូលទិន្នន័យខុសៗគ្នាត្រូវបានអនុវត្តក្នុងអំឡុងការអនុវត្តឆ្នាំ 2020 នៃគំរូបោះឆ្នោតដូចច្បាប់ VCA សម្រាប់ការបោះឆ្នោតខែវិច្ឆិកាឆ្នាំ 2020 នៅក្នុងខោនធី Sonoma ដើម្បីជួយដល់ ROV ឲ្យកែលម្អរបទពិសោធន៍ការបោះឆ្នោតសម្រាប់ការបោះឆ្នោតទាំងឡាយនាពេលអនាគត។ វិធីសាស្ត្រទាំងនេះ ក៏នឹងត្រូវប្រើក្នុងអំឡុងវដ្តបោះឆ្នោតនាពេលអនាគតផងដែរ។

1. *អ្នកវាយតម្លៃព័ត៌មានចុះឈ្មោះអ្នកបោះឆ្នោត* *(Clerk-Recorder Assessor IT, CRA-IT)*
   អ្នកវាយតម្លៃព័ត៌មានចុះឈ្មោះអ្នកបោះឆ្នោត (Clerk-Recorder Assessor IT, CRA-IT) បានជួលអ្នកបច្ចេកទេសបណ្តោះអាសន្នតាមគោលដៅតាមរយៈ Nelson Technology និង AppleOne ដើម្បីចុះមកកាន់មណ្ឌលបោះឆ្នោតក្នុងអំឡុងថ្ងៃបោះឆ្នោត ដើម្បីដោះស្រាយបញ្ហាបច្ចេកទេសនានា និងដើម្បីផ្តល់នូវមតិត្រឡប់ដល់ការិយាល័យគ្រប់គ្រងបរិក្ខារ ROV ដែលចាំបាច់ត្រូវធានាឲ្យមានសន្តិសុខ និងដាក់ពង្រាយទៅតាមទីតាំង ដើម្បីធានា ទីតាំងទាំងឡាយអាចផ្តល់នូវបទពិសោធន៍ដល់អ្នកបោះឆ្នោតឲ្យមានប្រសិទ្ធិភាពបំផុតតាមដែលអាចធ្វើទៅបាន។ ROV បានរៀនសូត្រ ទីតាំងបោះឆ្នោតមួយចំនួនមានចំនួនមនុស្សច្រើន និងបានសំណូមពរឲ្យដាក់ពង្រាយនូវឡែបថបបញ្ជីឈ្មោះអ្នកបោះឆ្នោតបន្ថែមទៀត និងម៉ាស៊ីនព្រីនសន្លឹកឆ្នោតចល័ត ដើម្បីឆ្លើយតបទៅនឹងបញ្ហា។ អ្នកបច្ចេកទេសអណ្តែតទាំងនេះក៏បានដោះស្រាយបញ្ហាបច្ចេកទេសនានានៅពេលដែលបុគ្គលិកបោះឆ្នោតរៀបចំបរិក្ខារមិនបានសមស្រប និងអាចដោះស្រាយបញ្ហា និងផ្តល់ព័ត៌មានដល់បុគ្គលិកបោះឆ្នោតពីការដំឡើងឲ្យបានសមស្របសម្រាប់ចំនួនថ្ងៃនៃការបោះឆ្នោតដែលនៅសល់។

2. *ការស្ទង់មតិបទពិសោធន៍គំរូ VCA*

ការស្ទង់មតិត្រូវបានបង្កើតឡើងសម្រាប់បុគ្គលិកបោះឆ្នោត បុគ្គលិកជំនួយតាមគោលដៅ និងបុគ្គលិកជំនួយផ្នែក ពត៌មានវិទ្យា ដើម្បីផ្តល់ព័ត៌មានដល់ ROV ឲ្យបានដឹងពីបទពិសោធន៍របស់គេប្រើប្រាស់គំរូបោះឆ្នោតដូចគ្នានឹងច្បាប់ VCA។ ការស្ទង់មិតិមានសំណួរទាំងឡាយពាក់ព័ន្ធដល់ការបណ្តុះបណ្តាលបុគ្គលិកតាមមណ្ឌលបោះឆ្នោត ឯកសារណែនាំទីតាំងបោះឆ្នោត សម្ភារផ្គត់ផ្គង់ដែលបានផ្តល់ឲ្យ និងកម្រិតពេញចិត្តជារួមជាមួយនឹងគំរូមណ្ឌលបោះឆ្នោត ឬទីតាំងជាក់លាក់ និងបុគ្គលិកមណ្ឌលបោះឆ្នោត។ ការស្ទង់មតិនឹងត្រូវប្រើដោយ ROV ដើម្បីកែលម្អការបណ្តុះបណ្តាលបុគ្គលិកមណ្ឌលបោះឆ្នោត និងកំណត់ឲ្យបាននូវបញ្ហាជាក់លាក់ទាក់ទៅនឹងទីតាំងមណ្ឌលបោះឆ្នោតនីមួយៗ ដូចជាការព្រួយបារម្ភពីការចតយានយន្ត និងបញ្ហាបរិក្ខារ។ នេះនឹងជួយក្នុងការរៀបចំការបោះឆ្នោតទាំងឡាយនាពេលអនាគត។

## B. អង្គភាពផ្តល់ប្រឹក្សា

នៅពេលដែលគណៈកម្មការប្រឹក្សាលទ្ធភាពចូលរួមបោះឆ្នោត (VAAC) និងគណៈកម្មការលទ្ធភាពចូលរួមផ្នែកភាសា (LAAC) ត្រូវបានបង្កើតឡើងនោះ ROV នឹងរៀបចំប្រជុំយ៉ាងតិចប្រចាំត្រីមាសរបស់គណៈកម្មការនីមួយៗ ដើម្បីពិភាក្សាពីប្រធានបទបោះឆ្នោតជាទូទៅដូចជា ឯកសារបោះឆ្នោត កិច្ចខិតខំប្រឹងប្រែងការអប់រំនិងផ្សព្វផ្សាយ ការព្រួយបារម្ភទៅលើសន្តិសុខតាមអ៊ីនធឺណិត និងសំណួរ ឬការព្រួយបារម្ភនានាចេញពីសាធារណជន។ គណៈកម្មការនេះនឹងផ្តល់មតិត្រឡប់អំពីមធ្យោបាយកែលម្អគំរូ VCA នៅក្នុងខោនធី Sonoma។ គណៈកម្មការទាំងនេះនឹងបន្តជួបជាទៀងទាត់ក្នុងអំឡុងវដ្តបោះឆ្នោតនាពេលអនាគត់ ហើយនឹងដាក់បញ្ចូលនូវសមាជិកពីសាធារណជន អ្នកតស៊ូមតិ និងអង្គការតាមសហគមន៍នានា។ នរណាម្នាក់ដែលមានបំណងចូលរួម នឹងចាំបាច់បំពេញនិងដាក់បញ្ជូនមកនូវពាក្យសុំចូលរួម។

## C. ការធ្វើចំណោលទៅលើមណ្ឌលបោះឆ្នោត &ហិបទម្លាក់សន្លឹកឆ្នោត

ក្រមបោះឆ្នោត 4005 (ច្បាប់ជម្រើសអ្នកបោះឆ្នោត) តម្រូវ ចំនួននៃមណ្ឌលបោះឆ្នោត និងហិបទម្លាក់សន្លឹកឆ្នោត ត្រូវផ្អែកទៅលើចំនួនអ្នកចុះឈ្មោះបោះឆ្នោតសរុបប្រចាំខោនធីក្នុងរយៈពេល 88 ថ្ងៃមុនការបោះឆ្នោត។ ដើម្បីធានាឲ្យមានការជ្រើសរើសបានគ្រប់គ្រាន់នូវមណ្ឌលបោះឆ្នោត និងហិបទម្លាក់សន្លឹកឆ្នោតនោះ ការស្ទង់មតិពីទីតាំងមានសក្តានុពលត្រូវបានធ្វើឡើងនៅក្នុងរដូវក្តៅ និងរដូវស្លឹកឈើជ្រុះឆ្នាំ 2020 ហើយមានបញ្ជាក់កន្លែងចំនួន 30 ដែលបានទទួល។ ROV បានប្រមើលមើល ការប្តូរមកកាន់ VCA នឹងជួយធានាបាននូវទីតាំងមណ្ឌលបោះឆ្នោតក្នុងរយៈពេលវែង។

បង្កើនក្នុងការចុះឈ្មោះបោះឆ្នោតមួយផ្នែកដោយសារតែការចុះឈ្មោះអ្នកបោះឆ្នោតធ្វើឡើងដោយស្វ័យប្រវត្តិតាមរយៈ DMV នឹងចាំបាច់ត្រូវត្រួតពិនិត្យមើល ដើម្បីធានា  យើងបង្កើនទីតាំងមណ្ឌលបោះឆ្នោតនិងហិបទម្លាក់សន្លឹកឆ្នោត នៅពេលចំនួនការចុះឈ្មោះឆ្លើយតបទៅនឹងចំនួនកំណត់ជាក់លាក់។ តាមការចុះឈ្មោះបច្ចុប្បន្នមានចំនួនជាង 303,000 លក្ខខណ្ឌតម្រូវគឺ៖

- ទីតាំងមណ្ឌលបោះឆ្នោត 31 ( 1 ក្នុងអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចចំនួន 10,000 នាក់ )
- ទីតាំងហិបទម្លាក់សន្លឹកឆ្នោត 21 ( 1ក្នុងអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចចំនួន 15,000 នាក់ )

ក្រមបោះឆ្នោត 4005 ក៏តម្រូវឲ្យខោនធីពិចារណាទៅលក្ខខណ្ឌតម្រូវជាក់លាក់នៅពេលកំណត់ទីតាំងមណ្ឌលបោះឆ្នោតសម្រាប់សហគមន៍។

លក្ខណៈវិនិច្ឆ័យដែលត្រូវពិចារណាគឺ៖

- មណ្ឌលបោះឆ្នោត និងកន្លែងហិបទម្លាក់សន្លឹកឆ្នោត នៅជិតមធ្យោបាយធ្វើដំណើរសាធារណៈ។
- មណ្ឌលបោះឆ្នោត និងកន្លែងហិបទម្លាក់សន្លឹកឆ្នោត នៅជិតសហគមន៍ដែលមានប្រវត្តិការបោះឆ្នោតទាបតាមរយៈការប្រើប្រាស់សំបុត្រ។
- មណ្ឌលបោះឆ្នោត និងកន្លែងហិបទម្លាក់សន្លឹកឆ្នោត នៅជិតមជ្ឈមណ្ឌលប្រជាជន។
- មណ្ឌលបោះឆ្នោត និងកន្លែងហិបទម្លាក់សន្លឹកឆ្នោត នៅជិតសហគមន៍និយាយភាសាជនជាតិភាគតិច។
- មណ្ឌលបោះឆ្នោត និងកន្លែងហិបទម្លាក់សន្លឹកឆ្នោត នៅជិតអ្នកបោះឆ្នោតជាជនពិការ។
- មណ្ឌលបោះឆ្នោត និងកន្លែងទម្លាក់ហិបសន្លឹកឆ្នោត នៅជិតសហគមន៍ដែលមានអត្រាទាបនៃភាពជាម្ចាស់យានយន្តក្នុងគ្រួសារ។
- មណ្ឌលបោះឆ្នោត និងកន្លែងទម្លាក់សន្លឹកឆ្នោត នៅជិតសហគមន៍ដែលមានប្រាក់ចំណូលទាប។
- មណ្ឌលបោះឆ្នោត និងកន្លែងហិបទម្លាក់សន្លឹកឆ្នោត នៅជិតសហគមន៍អ្នកបោះឆ្នោតស្របច្បាប់ដែលមិនត្រូវបានចុះឈ្មោះបោះឆ្នោត និងអាចត្រូវការសិទ្ធិទទួលបានការចុះឈ្មោះបោះឆ្នោតនៅថ្ងៃតែមួយ។

- មណ្ឌលបោះឆ្នោត និងកន្លែងហិបទម្លាក់សន្លឹកឆ្នោត នៅជិតប្រជាជនរស់នៅភូមិសាស្ត្រដាច់ស្រយាល រួមទាំងដែនដីជនជាតិអាមេរិកដើម។
- ងាយស្រួលក្នុងការចតយានជំនិះដោយមិនគិតថ្លៃ និងងាយស្រួលទៅកាន់ទីតាំងហិបទម្លាក់សន្លឹកឆ្នោត។
- ចម្ងាយ និងពេលវេលាដែលអ្នកបោះឆ្នោតត្រូវធ្វើដំណើរតាមរថយន្ត ឬមធ្យោបាយធ្វើដំណើរសាធារណៈទៅកាន់មណ្ឌលបោះឆ្នោត និងទីតាំងហិបទម្លាក់សន្លឹកឆ្នោត។
- តម្រូវការសម្រាប់វិធីសាស្ត្រផ្សេងៗសម្រាប់អ្នកបោះឆ្នោតជាជនពិការដែលបោះឆ្នោតតាមសំបុត្រមិនអាចចូលទៅបោះឆ្នោតបានទេ។
- គំរូចរាចរណ៍នៅជិតមណ្ឌលបោះឆ្នោត និងទីតាំងហិបទម្លាក់សន្លឹកឆ្នោត។
- តម្រូវការសម្រាប់មណ្ឌលបោះឆ្នោតចល័តបន្ថែមលើចំនួនមណ្ឌលបោះឆ្នោតដែលបានបង្កើតឡើង។
- ទីតាំងមណ្ឌលបោះឆ្នោតនៅសាកលវិទ្យាល័យសាធារណៈ ឬឯកជន ឬបរិវេណមហាវិទ្យាល័យ។

នៅមុនការបោះឆ្នោតខែវិច្ឆិកាឆ្នាំ 2020 ROVបានវិភាគទៅលើលក្ខខណ្ឌតម្រូវរបស់ VCA ជាមួយនឹង GIS ខោនធី ហើយបានបង្កើតឡើងនូវ ផែនទីដាក់ចេញនូវលក្ខខណ្ឌតម្រូវរបស់ VCA។ ROV បានប្រើប្រាស់ទិន្នន័យដើម្បីទំនាក់ទំនងទៅកាន់ទីតាំងដែលមានសក្តានុពលទាំងឡាយ ដើម្បីស្នើសុំការចូលរួមរបស់ពួកគេធ្វើជាមណ្ឌលបោះឆ្នោត និងធ្វើការតេស្តទៅការតភ្ជាប់វ៉ៃហ្វៃ ដើម្បីធានា ទីតាំងអាចប្រើប្រាសដំណោះស្រាយឧបករណ៍អេឡិចត្រូនិកដើម្បី 1) ផ្តល់សន្លឹកឆ្នោតដែលត្រឹមត្រូវសម្រាប់គ្រប់អ្នកបោះឆ្នោតទាំងអស់ ដោយមិនគិតមណ្ឌលបោះឆ្នោតមួយណាដែលពួកគេជ្រើសរើសទៅឡើយ និង 2) ដើម្បីធានាឲ្យបុគ្គលមណ្ឌលបោះឆ្នោតអាចកំណត់បានក្នុងករណីដែលអ្នកបោះឆ្នោតបានផ្ញើត្រឡប់មកវិញហើយនូវសន្លឹកឆ្នោត VBM មកកាន់ការិយាល័យរបស់យើង ឬ បានបោះឆ្នោតរួចហើយននៅមណ្ឌលបោះឆ្នោតមួយផ្សេងទៀតក្នុងកំឡុងពេលបោះឆ្នោត។ ទិន្នន័យដូចគ្នានេះត្រូវបានពិនិត្យឡើងវិញ ដើម្បីកំណត់សម្រាប់ទីតាំងហិបទម្លាក់សន្លឹកឆ្នោតងាយស្រួលបំផុត។

បញ្ជីពេញលេញនៃលក្ខខណ្ឌតម្រូវអប្បរមាសម្រាប់មណ្ឌលបោះឆ្នោតនិងព័ត៌មានវាយតម្លៃត្រូវបានដាក់នៅក្នុងឧបសម្ព័ន្ធ G។ បញ្ជីពេញលេញនៃលក្ខខណ្ឌតម្រូវអប្បរមាសម្រាប់ហិបទម្លាក់សន្លឹកឆ្នោត និងព័ត៌មានវាយតម្លៃត្រូវបានដាក់នៅក្នុងឧបសម្ព័ន្ធ H។

## D. បរិក្ខារនិងសន្តិសុខ

ដើម្បីធានា គ្រប់ទីតាំងទាំងស់មានបរិក្ខារបោះឆ្នោតគ្រប់គ្រាន់នោះ ROV មានបរិក្ខារបំរ៉ុងដើម្បីដាក់ពង្រាយតាមរយៈការប្រគល់ជូនដល់ដល់មន្ត្រីជំនួយតាមគោលដៅ (Field Support Officer, FSO) ឬ បុគ្គលិកវាយតម្លៃការកត់ត្រាផ្នែក ព័ត៌មានវិទ្យា (CRA-IT) ផ្តល់បច្ចេកទេសតាគោលដៅ។ CRA-IT បច្ចេកទេសតាមគោលដៅ ឬ FSO ត្រូវរាយការណ៍ទៅកាន់ ROV ប្រសិនបើទីតាំងត្រូវការឡែបថបបញ្ជីឈ្មោះអ្នកឆ្នោតបន្ថែម ឬ ម៉ាស៊ីនព្រីនសន្លឹកឆ្នោតចល័តបន្ថែម ដើម្បីឲ្យពួកគេអាចដាក់ពង្រាយបានភ្លាមៗទៅតាមតម្រូវការ។

បន្ថែមលើនេះទៀត ដើម្បីធានាឲ្យមានបរិក្ខារគ្រប់គ្រាន់នោះ ក៏ចាំបាច់ត្រូវមានតម្រូវការធានាដល់សន្តិសុខបរិក្ខារទាំអរស់ដែរ។ ROV បានស្នើសុំមតិត្រឡប់ពី និងពិនិត្យឡើងវិញលើ EAP នៃខោនធីផ្សេងទៀត ដើម្បីឲ្យដឹងពីអ្វីដែលពួកគេបានរៀនសូត្រនិងអ្វីជាការអនុវត្តដែលពួកគេកំពុងប្រព្រឹត្តិទៅ។ ROV ធ្វើបច្ចុប្បន្នភាពជាបន្តទៅគ្រប់កម្មវិធីនិងបរិក្ខារទាំងអស់ដូចត្រូវបានអនុញ្ញាតដោយច្បាប់រដ្ឋ និងតាមការចង្អុលបង្ហាញ និងជំនួយពីក្រុមផ្គត់ផ្គង់ប្រព័ន្ធអេឡិចត្រូនិករបស់យើងគឺ Dominion។ បន្ថែមលើនេះ កាំម៉េរ៉ាសុវត្ថិភាពបន្ថែមទៀតត្រូវបានដំឡើងតាមកន្លែងដំណើរការសន្លឹកឆ្នោត។ ការថែទាំជាលក្ខណៈអភិរក្សក៏ត្រូវបានអនុវត្តចំពោះបរិក្ខារបោះឆ្នោតស្របទៅតាមនីតិវិធីប្រើប្រាស់បរិក្ខារ។

ការរៀបចំនៃបរិក្ខារបោះឆ្នោតត្រូវបានធ្វើឡើងដោយអ្នកសម្របសម្រួលនាយកដ្ឋានប្រព័ន្ធព័ត៌មាន ROV អ្នកបច្ចេកទេសនាយកដ្ឋានឯកទេសព័ត៌មាន ប្រធានគ្រប់គ្រងសន្និធិប្រធានគ្រប់គ្រងឃ្លាំង aka និងបុគ្គលិកជំនួយបន្ថែមទៀត។ ការប្រគល់ជូននៃបរិក្ខារត្រូវបានសម្របសម្រួលរវាងអនុប្រធាន ROV, ប្រធានកាន់សន្និធិ, និងក្រុមហ៊ុនដឹកជញ្ជូន ដែលនឹងត្រូវចុះកិច្ចសន្យាដើម្បីប្រគល់បរិក្ខាបោះឆ្នោតនិងសម្ភារៈទាំងឡាយដោយសុវត្ថិភាពដល់មណ្ឌលបោះឆ្នោតសម្រាប់ ROV។

ការបញ្ជូនមកដល់នៃបរិក្ខារនិងសម្ភារបោះឆ្នោតត្រូវបានរៀបចំឡើងរវាងក្រុមហ៊ុនដឹកជញ្ជូន និងទីតាំងមណ្ឌលបោះឆ្នោត និងទាន់ពេលសម្រាប់ការបោះឆ្នោតមុនបើកដំណើរការ ដែលកើតឡើង 10 ឬ 3 ថ្ងៃមុនថ្ងៃបោះឆ្នោតនោះ

បរិក្ខារត្រូវបានរក្សាទុកដាក់នៅតាមទីតាំងមណ្ឌលបោះឆ្នោតក្នុងកន្លែងដែលត្រូវបានរៀបចំទុកជាមុនរវាងក្រុមហ៊ុនដឹកជញ្ជូន និងទីតាំងមណ្ឌលបោះឆ្នោត ហើយបរិក្ខារទាំងអស់ត្រូវចាក់សោរតាមបច្ចេកទេសនៅគ្រប់ស្បោងសម្ភារៈទាំងអស់ រទេះ ឬ ទូរដាក់ ដែលត្រូវបានកត់ត្រានិងពិនិត្យទៅតា

មដំណើរការសន្តិសុខសម្រាប់ទីតាំងបោះឆ្នោត ដោយបុគ្គលិកមណ្ឌលបោះឆ្នោត ដែលបើកមណ្ឌលបោះឆ្នោតនៅថ្ងៃទីមួយនៃការបោះឆ្នោតមុន។

បរិក្ខារទាំងអស់ត្រូវបានរក្សាសន្តិសុខដោយបុគ្គលិកមណ្ឌលបោះឆ្នោតដោយការចាក់សោរតាមបច្ចេកទេសនិងដែលកំណត់នៅចន្លោះថ្ងៃបោះឆ្នោត និងវត្តមានដែលត្រូវបានបញ្ជាក់នៅពេលបើកមណ្ឌលបោះឆ្នោតនៅថ្ងៃបោះឆ្នោតជាបន្តបន្ទាប់។

### E. ការផ្សព្វផ្សាយ & ការអប់រំ

ROV នឹងបន្តអប់រំនិងផ្សព្វផ្សាយដល់សហគមន៍ផ្សេងៗគ្នាពាក់ព័ន្ធដល់ជម្រើសការបោះឆ្នោតស្ថិតក្រោមច្បាប់ VCA។ ផែនការនេះអាចរកឃើញនៅទំព័រលេខ 4 និងលេខ 5 នសឯកសារនេះ។

## III. <u>សកម្មភាពបោះឆ្នោត & ការគាំទ្រ</u>

### A. ការធ្វើតេស្តពី តក្កវិជ្ជា & ភាពត្រឹមត្រូវ

បរិក្ខារទាំងអស់នឹងត្រូវរៀបចំទ្បំឡើងដោយអ្នកសម្របសម្រួលនាយកដ្ឋានសេវាព័ត៌មានរបស់ ROV, អ្នកបច្ចេកទេសនាយកដ្ឋានអ្នកឯកទេសព័ត៌មាន ប្រធានគ្រប់គ្រងសន្និធិ និងបុគ្គលិកជំនួយបន្ថែមសម្រាប់ការបោះឆ្នោតនីមួយៗ ក្រោយពីទទួលបានបញ្ជីឈ្មោះបេក្ខជនដែលត្រូវបញ្ជាក់ពីលេខារដ្ឋ (សម្រាប់ការបោះឆ្នោតទូទាំងរដ្ឋ) និងបញ្ជីនៃបេក្ខជនដែលត្រូវបានរៀបចំឡើងដោយបុគ្គលិក ROV សម្រាប់ការបោះឆ្នោតក្នុងមូលដ្ឋាន។ ការធ្វើតេស្តលើតក្កវិជ្ជ & ភាពត្រឹមត្រូវនឹងត្រូវធ្វើឡើងស្របទៅតាមច្បាប់រដ្ឋសម្រាប់បរិក្ខារបោះឆ្នោតទាំងអស់ រួមបញ្ចូលទាំងម៉ាស៊ីនព្រីនសន្លឹកឆ្នោត ឧបករណ៍គូសសន្លឹកឆ្នោតដែលបានប្រើប្រាស់បាន និងម៉ាស៊ីនស្កែនសន្លឹកឆ្នោត។ សេចក្តីប្រកាសព័ត៌មានត្រូវបានបញ្ជូនទៅមុនការចាប់ផ្តើមនៃការធ្វើតេស្តតក្កវិជ្ជា & ភាពត្រឹមត្រូវ។ ដំណើរការនេះបើកទៅដល់សាធារណជន។

### B. សម្ភារៈបោះឆ្នោត & ធនធាន

1. *សៀវភៅណែនាំព័ត៌មានអ្នកបោះឆ្នោតខោនធី*

   សៀវភៅណែនាំអ្នកបោះឆ្នោតខោនធី (CVIG) របស់ ROV នឹងមានផ្ទុកនូវរូបភាពសន្លឹកឆ្នោតគំរូសម្រាប់ប្រភេទសន្លឹកឆ្នោតជាក់លាក់របស់អ្នកបោះឆ្នោតនីមួយៗសម្រាប់ការបោះឆ្នោត។ សៀវភៅណែនាំនេះ នឹងមានផងដែរនូវព័ត៌មានលម្អិតអំពីដំណើរការបោះឆ្នោតតាមសំបុត្រ និងជម្រើសទាំងឡាយសម្រាប់ធ្វើការស្នើសុំសន្លឹកឆ្នោត VBM ជំនួសថ្មី និងសម្រាប់ធ្វើការបញ្ជូនត្រឡប់មកវិញនូវសន្លឹកឆ្នោត VBM រួមទាំងបញ្ជីពេញលេញនៃទីតាំងមណ្ឌលបោះឆ្នោត

និងហិបទម្លាក់សន្លឹកឆ្នោត។ សៀវភៅណែនាំមានផ្តល់ជូនទាំងទម្រង់បោះពុម្ពទំហំអក្សរធំ និងអនឡាញ។

សៀវភៅណែនាំព័ត៌មានអ្នកបោះឆ្នោតខោនធីដែលអាចទទួលបានមាននៅលើគេហទំព័ររបស់ ROV ចាប់ផ្តើម 45 ថ្ងៃ មុនថ្ងៃបោះឆ្នោត។ ដើម្បីចូលមើលសៀវភៅពត៌មានអ្នកបោះឆ្នោតរដ្ឋដែលមានពត៌មានអំពីបេក្ខជន និងសំណើទូទាំងរដ្ឋ សូមចូលទៅកាន់ [https://www.sos.ca.gov/elections/](https://www.sos.ca.gov/elections/)។

2. *កញ្ចប់បោះឆ្នោតតាមសន្លឹកឆ្នោតផ្ញើតាមប៉ុស្តិ៍*

   រាល់អ្នកបោះឆ្នោតទាំងអស់ដែលបានចុះឈ្មោះរួចនៅក្នុងខោនធី Sonoma នឹងទទួលបានកញ្ចប់បោះឆ្នោតតាមសំបុត្រមួយកញ្ចប់នៅក្នុងសំបុត្រ។ កញ្ចប់នេះនឹងរួមបញ្ចូលនូវសន្លឹកឆ្នោតផ្លូវការ ការណែនាំអំពីការបោះឆ្នោត ស្រោមសំបុត្រពណ៌ខៀវត្រូវផ្ញើត្រឡប់មកវិញ បញ្ជីឈ្មោះទីតាំងហិបទម្លាក់សន្លឹកឆ្នោតនិងទីតាំងមមណ្ឌលបោះឆ្នោតទាំងអស់ និងស្ទីកឺ "ខ្ញុំបានបោះឆ្នោតរួច" មួយ។ ឯកសារបោះឆ្នោតដូចជា សន្លឹកឆ្នោតផ្លូវការ មិនត្រូវបានបញ្ជូនបន្តដោយសេវាលប្រៃសណីយ៍អាមេរិកទេ (ក្រមបោះឆ្នោត 3008[b])។ ពួកគេត្រូវបានបញ្ជូនទៅកាន់ ROV សម្រាប់ការធ្វើដំណើរការ។

3. *ប័ណ្ណប្រៃសណីយ៍អ្នកបោះឆ្នោត*

   អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចទាំងអស់ នឹងទទួលបានប័ណ្ណប្រៃសណីយ៍ពីរជូនដំណឹងដល់អ្នកបោះឆ្នោតពីការបោះឆ្នោតនឹងចូលមកដល់ និងព័ត៌មានទំនាក់ទំនង។ ប័ណ្ណប្រៃសណីយ៍ទីមួយ នឹងត្រូវបានផ្ញើទៅកាន់អ្នកបោះឆ្នោតតាមសំបុត្រមុនសៀវភៅណែនាំព័ត៌មានអ្នកបោះឆ្នោតប្រចាំខោនធី និងប័ណ្ណប្រៃសណីយ៍ទីពីរ នឹងត្រូវផ្ញើទៅកាន់អ្នកបោះឆ្នោតតាមសំបុត្រ 11 ថ្ងៃមុនថ្ងៃបោះឆ្នោតបើដំណើរការ។

4. *[គេហទំព័រ ROV]()*

   ចាប់ផ្តើម 29 ថ្ងៃមុនថ្ងៃបោះឆ្នោត គេហទំព័រ ROV នឹងត្រូវបានធ្វើបច្ចុប្បន្នភាពដោយមានព័ត៌មានដូចខាងក្រោម៖

   a. [ឧបករណ៍រកមើលអ្នកបោះឆ្នោត]() ដែលអនុញ្ញាតឲ្យអ្នកបោះឆ្នោតខោនធី Sonoma៖
      - ផ្ទៀងផ្ទាត់ព័ត៌មានចុះឈ្មោះអ្នកបោះឆ្នោតរបស់គេ

▪ ផ្ទៀងផ្ទាត់នូវសន្លឹកឆ្នោតដែលបានបោះហើយរបស់គេ ដែលត្រូវបានទទួលដោយខោនធី Sonoma
▪ ស្វែងរកមណ្ឌលបោះឆ្នោតដែលស្ថិតនៅជិតបំផុតទៅនឹងលំនៅដ្ឋានរបស់គេ
▪ ចូលទៅកាន់សៀវភៅណែនាំព័ត៌មានអ្នកបោះឆ្នោតប្រចាំខោនធីរបស់គេ និង

b. ទីតាំងមណ្ឌលបោះឆ្នោត និងហិបទម្លាក់សន្លឹកឆ្នោតកំណត់ទៅតាមទីក្រុង ដោយមានចំនួនម៉ោងនៃប្រតិបត្តិការ និងទិសដៅទៅកាន់ទីតាំងណាមួយតាមរយៈ Google Maps។
c. លទ្ធផលបោះឆ្នោតដែលមានអន្តរកម្ម
d. កញ្ចប់ឧបករណ៍អនឡាញសម្រាប់ឯកសារផ្សព្វផ្សាយ និងឯកសារបោះពុម្ពពាក់ព័ន្ធដល់ច្បាប់ជម្រើសអ្នកបោះឆ្នោត
e. ព័ត៌មានស្តីពី ជម្រើសដែលអាចចូលរួមបានក្នុងការបោះឆ្នោត រួមមានព័ត៌មានអំពីអ្វីដែលមានផ្តល់ជូននៅតាមមណ្ឌលបោះឆ្នោត ការបោះឆ្នោតដោយស្នើសុំឲ្យអ្នកផ្សេងយកសន្លឹកឆ្នោតមកឲ្យ ការបោះឆ្នោតដែលអាចធ្វើបានសំបុត្រ និងឯកសារទាំងឡាយនៅក្នុងទម្រង់ដែលអាចប្រើប្រាស់បាន។

## C. ជម្រើបោះឆ្នោត & ការទទួលបានសន្លឹកឆ្នោត

1. *បោះឆ្នោតតាមសំបុត្រ*

អ្នកបោះឆ្នោតអាចជ្រើសរើសបោះឆ្នោតនូវសន្លឹកឆ្នោតផ្លូវការរបស់គេ មាននៅក្នុងកញ្ចប់បោះឆ្នោតតាមសំបុត្រចាប់ផ្តើមឡើង 29 ថ្ងៃមុនថ្ងៃបោះឆ្នោត។ ពួកគេអាចផ្ញើត្រឡប់មកវិញនូវសន្លឹកឆ្នោតរបស់គេតាមរយៈសំបុត្រ នៅតាមហិបទម្លាក់សន្លឹកឆ្នោតណាមួយចាប់ផ្តើម 29 ថ្ងៃមុនថ្ងៃបោះឆ្នោត ឬ នៅតាមមណ្ឌលបោះឆ្នោតណាមួយ។ ការជំនួសសន្លឹកឆ្នោតថ្មីអាចមានផ្តល់ជូននៅការិយាល័យ ROV និងនៅតាមមណ្ឌលបោះឆ្នោត។

ប្រសិនបើអ្នកបោះឆ្នោតមិនទទួលបាននូវកញ្ចប់បោះឆ្នោតតាមសំបុត្ររបស់គេទេ ពួកគេអាចទូរសព្ទមកកាន់ការិយាល័យតាមលេខ (707) 565-6800 ឬ តាមប្រព័ន្ធទូរសព្ទឥតគិតថ្លៃលេខ (800) 750-8683 ដើម្បីស្នើសុំជំនួសកញ្ចប់ថ្មី ឬ មកកាន់ការិយាល័យ ROV ដោយផ្ទាល់។ កញ្ចប់បោះឆ្នោតតាមសំបុត្ររបស់អ្នកបោះឆ្នោត អាចត្រូវបានមកទទួលយកនៅការិយាល័យ ROV ដោយមិត្តភក្តិ ឬសាច់ញាតិ ក្នុងករណីដែលអ្នកបោះឆ្នោតបំពេញទ

ម្រង់អនុញ្ញាបន្ទាន់សម្រាប់ការមកទទួលសន្លឹកឆ្នោត ដែលមានផ្តល់នៅលើគេហទំព័ររបស់លេខារដ្ឋកាលីហ្វ័រញ៉ា។

បោះឆ្នោតតាមសំបុត្រអាចនឹងត្រូវផ្ញើត្រឡប់មកវិញតាមសំបុត្រ (បង់ថ្លៃផ្ញើរួចជាស្រេច) នៅតាមមណ្ឌលបោះឆ្នោតណាមួយ ឬ នៅតាមហិបទម្លាក់សន្លឹកឆ្នោតណាមួយរហូតដល់ម៉ោង 8:00 យប់ នៅថ្ងៃបោះឆ្នោត។ ប្រសិនបើអ្នកបោះឆ្នោតភ្លេចចុះហត្ថលេខានៅលើសន្លឹកឆ្នោតបញ្ជូនត្រឡប់តាមសំបុត្រមកនោះ ឬក្នុងករណីដែលដែលហត្ថលេខារបស់គេដែលបានផ្តល់នៅលើស្រោមសំបុត្រផ្ញើត្រឡប់មកវិញមិនត្រូវគ្នាទៅនឹងហត្ថលេខានៅលើសំណុំឯកសារអ្នកបោះឆ្នោតរបស់គេនោះ ROV នឹងផ្ញើសំបុត្រទៅកាន់អ្នកបោះឆ្នោតដែលរួមបញ្ចូលនូវសេចក្តីណែនាំពីរបៀបកែតម្រូវបញ្ហា និងពីកាលបរិច្ឆេទផុតកំណត់ដើម្បីជួសជុលស្ថានការ។ សន្លឹកឆ្នោតដែលចាត់ទុកជាបានការដែលបានវាយត្រាដោយប្រៃសណីយ៍នៅចំថ្ងៃ ឬ មុនថ្ងៃបោះឆ្នោត ហើយបានទទួលនៅការិយាល័យ ROV នៅក្នុងរយៈពេលត្រឹមត្រូវតាមច្បាប់ដែលបានអនុញ្ញាតបន្ទាប់ពីការបោះឆ្នោត នឹងត្រូវបានរាប់និងបូកបញ្ចូលទៅក្នុងលទ្ធផលផ្លូវការ។

មណ្ឌលបោះឆ្នោតបើកពីម៉ោង 9:00 ព្រឹក ដល់ម៉ោង 5:00 ល្ងាច ក្នុងអំឡុងថ្ងៃបោះឆ្នោតទាំងអស់នៃការបោះឆ្នោតមុន។ អ្នកបោះឆ្នោតអាចផ្ទៀងផ្ទាត់ម៉ោងបោះឆ្នោត និងទីទាំងបោះឆ្នោតមុនពេលមក ដោយពិនិត្យឡើងវិញនៅលើសៀវភៅណែនាំព័ត៌មានអ្នកបោះឆ្នោតប្រចាំខោនធីរបស់គេ កញ្ចប់បោះឆ្នោតតាមសំបុត្រ ទូរសព្ទមកកាន់លេខ (707) 565-6800 ឬ នៅលើគេហទំព័ររបស់ ROV។ មណ្ឌលបោះឆ្នោតទាំងអស់បើដំណើរការពីម៉ោង 7:00 ព្រឹក រហូតដល់ម៉ោង 8:00 យប់នៅថ្ងៃបោះឆ្នោត។ ទីតាំងហិបទម្លាក់សន្លឹកឆ្នោតទាំងអស់ត្រូវបានបើក 28 ថ្ងៃមុនការបោះឆ្នោតនីមួយៗ ត្រូវបានបើក 24 ម៉ោងឈានដល់ថ្ងៃបោះឆ្នោត ហើយត្រូវបានចាក់សោរនៅម៉ោង 8 យប់នៅថ្ងៃបោះឆ្នោត។

នៅសន្លឹកឆ្នោតបានបញ្ជូនមកកាន់ការិយាល័យ ROV ភ្លាម ការពិនិត្យលើហត្ថលេខនៅលើសន្លឹកឆ្នោតផ្លូវការនឹងត្រូវបានចាប់ផ្តើម យ៉ាងលឿនបំផុត 28 ថ្ងៃមុនថ្ងៃបោះឆ្នោត។ រាល់សន្លឹកឆ្នោតទាំងអស់ដែលត្រូវបានបញ្ជូនមកតាមសំបុត្រ ត្រូវបានពិនិត្យហត្ថលេខាជាមួយនឹងហត្ថលេខានៅលើឯកសារចុះឈ្មោះអ្នកបោះឆ្នោត និងឯកសារគាំទ្រនានារបស់គេ។ សន្លឹកឆ្នោតបោះតាមសំបុត្រមិនបន្តរហូតត្រូវទាញចេញ ឬ ដំណើរការរហូតដល់ទាល់តែ ROV កំណត់ ហត្ថលេខត្រូវគ្នា។ សន្លឹកឆ្នោតបោះតាមសំបុត្រដែលមានបញ្ហាចោទទាំងអស់ ដូចជាហត្ថលេខាមិនត្រូវគ្នាជាដើម តម្រូវឲ្យ_ ក់គ្រប់គ្រងពិនិត្យឡើងវិញ។ ប្រសិនបើអ្នកបោះឆ្នោតមិនបា

នផ្តល់ហត្ថលេខារបស់គេ ឬក្នុងករណីដែលហត្ថលេខារបស់គេមិនត្រូវគ្នានោះ អ្នកបោះឆ្នោតនឹងត្រូវបានទាក់ទងតាមសំបុត្រដើម្បីឲ្យកែតម្រូវបញ្ហានៅមុនការបញ្ជាក់នៃការបោះឆ្នោត។

2. *ការបោះឆ្នោតដែលអាចធ្វើបានតាមសំបុត្រ*

អ្នកបោះឆ្នោតដែលមានពិការភាព អាចចូលទៅកាន់កម្មវិធីគូសសន្លឹកឆ្នោតតាមសំបុត្រដោយការចូលរួមបោះឆ្នោតពីចម្ងាយ (RAVBM) ដោយបំពេញពាក្យសុំនៅ [គេហទំព័រ ROV] ឬដោយការបំពេញពាក្យសុំនៅលើខ្នងនៃសៀវភៅណែនាំព័ត៌មានអ្នកបោះឆ្នោតប្រចាំខោនធី។ នៅពេលអ្នកបោះឆ្នោតបំពេញនិងដាក់បញ្ជូនពាក្យសុំភ្លាម ROV នឹងបញ្ជូនសំណុំព័ត៌មានអ្នកបោះឆ្នោតទៅកាន់ប្រព័ន្ធបោះឆ្នោត Dominion ដែលបង្ហោះវេទិការ ROV RAVBM ភ្លាម ហើយអ្នកបោះឆ្នោតនឹងទទួលបាននូវអ៊ីម៉ែលណែនាំអ្នកបោះឆ្នោតពីរបៀបត្រូវដំណើរការ។ នៅពេលនោះ អ្នកបោះឆ្នោតនឹងត្រូវណែនាំក្នុងអ៊ីម៉ែលពីរបៀបទទួលបានកញ្ចប់សន្លឹកឆ្នោតរបស់គេ ដោយផ្អែកទៅលើអាសយដ្ឋានលំនៅដ្ឋានរបស់គេ ហើយអាចស្វែងរកសន្លឹកឆ្នោតអេឡិចត្រូនិកដោយប្រើប្រាស់ក្តាចុច ម៉ៅស៍ អេក្រង់ប៉ះ ឬ នៅលើឧបករណ៍ជំនួយផ្ទាល់ខ្លួនរបស់គេ។ នៅពេលអ្នកបោះឆ្នោតបានបំពេញចប់សព្វគ្រប់នូវការគូសលើសន្លឹកឆ្នោតរបស់គេរួចរាល់ហើយ ពួកគេនឹងមានជម្រើសត្រួតពិនិត្យឡើងវិញនូវការជ្រើសរើសរបស់គេ។ នៅពេលដែលជម្រើសរបស់គេត្រូវបានកំណត់ជាចុងក្រោយរួចមក អ្នកបោះឆ្នោតត្រូវព្រីនសន្លឹកឆ្នោតរបស់គេចេញ ហើយត្រូវផ្ញើវាដោយប្រើស្រោមសំបុត្របញ្ជូនត្រឡប់ពណ៌ខៀវរបស់គេដែលត្រូវបានផ្ញើទៅឲ្យពួកគេ ការជំនួសស្រោមសំបុត្រថ្មីដែលអាចទទួលបាននៅការិយាល័យ ROV ឬ នៅតាមមណ្ឌលបោះឆ្នោតណាមួយក៏បាន ឬ ទម្រង់ស្រោមសំបុត្រដែលអាចព្រីនបាននៅលើអនឡាញ រួមបញ្ចូលទាំងសេចក្តីណែនាំទាំងឡាយផងដែរ។

3. *មណ្ឌលបោះឆ្នោត*

ពលរដ្ឋខោនធី Sonoma ទាំងឡាយដែលមានសិទ្ធិ អាចមកកាន់មណ្ឌលបោះឆ្នោតណាមួយក៏បានចាប់ផ្តើម 10 ថ្ងៃមុនថ្ងៃបោះឆ្នោតដើម្បី៖

- បោះឆ្នោតដោយផ្ទាល់
- មកទទួលយកសន្លឹកឆ្នោតជំនួសថ្មីដោយខ្លួនឯង ឬមានអ្នកផ្សេង (ទម្រង់អនុញ្ញាតបន្ថែមមកទទួលយកត្រូវបំពេញ និងមានផ្តល់នៅការិយាល័យ ROV ឬ អាចត្រូវបញ្ជូនទៅកាន់អ្នកបោះឆ្នោត ឬ សេចក្តីថ្លែងដែលមានចុះហត្ថលេខាពីអ្នកបោះឆ្នោត)។ សន្លឹកឆ្នោតផ្លូវការជំនួសថ្មី ត្រូវបានព្រីនដោយប្រើប្រាស់ម៉ាស៊ីនព្រីនសន្លឹកឆ្នោតចល័ត បញ្ជាក់ដោយលេខារដ្ឋ។

- ទម្លាក់សន្លឹកឆ្នោត VBM ដែលត្រូវបានបោះ
- ប្រើប្រាស់ឧបករណ៍ដែលហៅ ImageCast X (ICX) គូសលើសន្លឹកឆ្នោតដែលទទួលបាន ប៉ុន្តែរួមបញ្ចូលផ្ទាំងអេក្រង់ដែលប៉ះបាន ផ្ទាំងចុចមានអក្សរសម្រាប់ជនពិការភ្នែក សម្លេងជាភាសាអង់គ្លេស និងធាតុចូលសម្រាប់ប្រាស់ឧបករណ៍បច្ចេកវិទ្យាជំនួយដូចជាប្រដាប់ធាក់ ស្រូប និងផ្លុំ (អ្នកបោះឆ្នោតត្រូវតែមានបច្ចេកវិទ្យាជំនួយផ្ទាល់ខ្លួន)។
- ទទួលជំនួយជាភាសាផ្សេងក្រៅពីភាសាអង់គ្លេស
- ចុះឈ្មោះបោះឆ្នោតសម្រាប់លើដំបូង ឬ ធ្វើបច្ចុប្បន្នភាពការចុះឈ្មោះអ្នកបោះឆ្នោតដោយប្រើការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌ (Conditional Voter Registration, CVR)។ សន្លឹកឆ្នោត CVR ទាំងអស់ដែលបានបោះរួចត្រូវបានដាក់ចូលទៅក្នុងស្រោមសំបុត្រពណ៌ផ្កាឈូក ត្រូវដំណើរការនៅការិយាល័យ ROV ក្នុងអំឡុងពេលបូកសរុបសន្លឹកឆ្នោត។

អ្នកបោះឆ្នោតអាចមកាន់ទីតាំងណាមួយដើម្បីទទួលបាននូវប្រភេទសន្លឹកឆ្នោតត្រឹមត្រូវរបស់គេ។ មណ្ឌលបោះឆ្នោតទាំងអស់បើកដំណើរការយ៉ាងហោចណាស់ 8ម៉ោងក្នុងមួយថ្ងៃក្នុងអំឡុងពេលបោះឆ្នោតមុន ចាប់ពីម៉ោង 9:00 ព្រឹកដល់ម៉ោង 5:00 ល្ងាច និងមណ្ឌលបោះឆ្នោតទាំងអស់ត្រូវបើកដំណើរការពីម៉ោង 7:00 ព្រឹកដល់ម៉ោង 8:00 យប់នៅថ្ងៃបោះឆ្នោត។

អ្នកបោះឆ្នោតត្រូវចុះឈ្មោះចូលមណ្ឌលបោះឆ្នោតដោយបុគ្គលិកមណ្ឌលបោះឆ្នោតតាមរយៈធ័រថលដែលមានសន្តិសុខមួយ ដើម្បីចូលទៅកាន់សំណុំឯកសារអ្នកបោះឆ្នោត។ ប្រសិនបើអ្នកបោះឆ្នោតបានផ្ញើត្រឡប់មកវិញនូវសន្លឹកឆ្នោតនោះ (ហត្ថលេខាត្រូវបានពិនិត្យ "ល្អ") ពួកគេនឹងមិនអាចទទួលបានសន្លឹកឆ្នោតជំនួសថ្មីនោះទេ។ ប្រសិនបើសន្លឹកឆ្នោតមិនទាន់បានបញ្ចូលត្រឡប់មក ឬបានបញ្ជូនមក "មានបញ្ហាចោទ" នោះ អ្នកបោះឆ្នោតអាចនឹងទទួលបានសន្លឹកឆ្នោតជំនួសថ្មី ដែលពេលនោះនឹងបញ្ចាសនូវសន្លឹកឆ្នោតផ្សេងទៀត ដែលត្រូវបានចេញទៅឲ្យអ្នកបោះឆ្នោតនោះ។ នៅពេលដែលអ្នកសន្លឹកឆ្នោតត្រូវបានបញ្ជូនត្រឡប់មកដោយមធ្យោបាយណាមួយ ដោយផ្ទាល់ ឬ ប្រើប្រាស់សន្លឹកឆ្នោតតាមសំបុត្ររបស់គេនោះ សន្លឹកឆ្នោតផ្សេងទៀតត្រូវបានកំណត់ថាពុំមានសុពលភាពដោយស្វ័យប្រវត្តិ។

អ្នកបោះឆ្នោតភាគច្រើននឹងមិនផ្តល់នូវអត្តសញ្ញាណនៅពេលគេបោះឆ្នោតដោយផ្ទាល់។ សូមចូលទៅកាន់ រដ្ឋលេខាធិការសម្រាប់ព័ត៌មានបន្ថែម រួមទាំងបញ្ជីរាយអត្តសញ្ញាណដែលអាចទទួលយកបាន។

ការបោះឆ្នោតទាំងអស់ត្រូវបានធ្វើឡើងនៅតាមមណ្ឌលបោះឆ្នោត ស្របទៅតាមស្តង់ដាសន្តិសុខរបស់លេខារដ្ឋ នីតិវិធីសន្តិសុខរបស់ ROV និងបទបញ្ញត្តិនៅក្នុងក្រមបោះឆ្នោតរដ្ឋកាលីហ្វ័រញ៉ា និងនីតិវិធីប្រើប្រាស់ប្រព័ន្ធបោះឆ្នោតកាលីហ្វ័រញ៉ា។ នេះរួមបញ្ចូល ដោយមិនកំណត់ ដោយធានាឲ្យបាននូវបរិក្ខារទាំងអស់នៅតាមមណ្ឌលបោះឆ្នោតត្រូវបានបិទភ្ជាប់ រក្សាទុក ត្រូវបានបញ្ជូនមក និងប្រើប្រាស់ស្របទៅតាមបទបញ្ញត្តិទាំងនេះ។ បន្ថែមលើនេះ នីតិវិធីបច្ចុប្បន្នរបស់យើងតម្រូវឲ្យបុគ្គលិកបោះឆ្នោតភាគច្រើនមានវត្តមាននៅពេលទីតាំងបើកដំណើរការ។

សន្លឹកឆ្នោតទាំងអស់ដែលបានបោះត្រូវបានផ្ញើត្រឡប់មកវិញនៅពេលយប់ទៅកាន់ការិយាល័យ ROV ព្រមជាមួយនឹងសន្លឹកបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលមានផ្ទុកនូវហត្ថលេខាអ្នកបោះឆ្នោតនិងសន្លឹកឆ្នោតដែលខូច។ ក្រដាសសន្លឹកឆ្នោតទទេ ត្រូវបានរក្សាទុកដោយសុវត្ថិភាពនៅពេលយប់នៅតាមមណ្ឌលបោះឆ្នោត។

ការរៀបបញ្ជីទាំងអស់ត្រូវបានធ្វើឡើងនៅការិយាល័យ ROV។ ពុំមានម៉ាស៊ីនតារាងបញ្ជីនៅតាមមណ្ឌលបោះឆ្នោតណាមួយឡើយ។ អ្នកបោះឆ្នោតទាំងអស់ត្រូវបោះឆ្នោតជាសន្លឹកឆ្នោតក្រដាសដែលត្រូវបានព្រីនចេញ។

ស្ថិតក្រោមលក្ខខណ្ឌតម្រូវប្រព័ន្ធបោះឆ្នោតរដ្ឋកាលីហ្វ័រញ៉ា បរិក្ខារទាំងអស់ដែលត្រូវបានបញ្ជាក់ ត្រូវប្រើថ្មនៅក្នុងករណីដែលដាច់ភ្លើង។ ទីតាំងទាំងអស់នឹងមានទូសព្វដៃមួយគ្រឿង។ ការពង្រឹងការអនុវត្តច្បាប់នឹងទទួលបានបញ្ជីមួយនៃទីតាំងមណ្ឌលបោះឆ្នោតទាំងអស់។ មណ្ឌលបោះឆ្នោតនីមួយៗនឹងត្រូវបានផ្តល់ដោយនីតិវិធីបន្ទាន់ និងត្រូវបានផ្តល់ដោយសៀវភៅណែនាំប្រតិបត្តិសម្រាប់ប្រតិបត្តិការនៃមណ្ឌលបោះឆ្នោតនិងការដំណើរការអ្នកបោះឆ្នោត។

ROV នឹងធ្វើការភ្លាមៗដើម្បីដោះស្រាយបញ្ហារអាក់រអួលនានានៅតាមមណ្ឌលបោះឆ្នោត និងបញ្ហារអាក់រអួលនីមួយៗនឹងមានការឆ្លើយតបផ្ទាល់ខ្លួនរបស់វា។ ជាទូទៅ ប្រសិនបើមណ្ឌលបោះឆ្នោតណាមួយត្រូវមានបញ្ហារអាក់រអួលនោះ ROV នឹងមានបុគ្គលិកបង្វែរអ្នកបោះឆ្នោតទាំងឡាយទៅកាន់មណ្ឌលបោះឆ្នោតផ្សេងទៀតភ្លាមៗ ហើយនឹងជូនដំណឹងដល់ប៉ូលីសក្នុ

ងមូលដ្ឋាន ការិយាល័យលេខារដ្ឋ និងផ្តល់បច្ចុប្បន្នភាពតាមប្រព័ន្ធផ្សព្វផ្សាយដើម្បីធានា អ្នកបោះឆ្នោតទទួលបានព័ត៌មាន។ ប្រសិនបើមានគ្រោះមហន្តរាយធម្មជាតិ ឬការរំខានផ្សេងកើតឡើង ដែលប៉ះពាល់ដល់មណ្ឌលបោះឆ្នោត ឬ ទីតាំងជារូបវន្តរបស់កន្លែងហិបទម្លាក់សន្លឹកឆ្នោត ការជូនដំណឹងបន្ថែម ស្លាកសញ្ញា និងបុគ្គលិកនៅជួយណែនាំអ្នកបោះឆ្នោតទៅទីតាំងជាជម្រើសមួយ។ ប្រសិនបើសកម្មភាពទាំងអស់នៅមណ្ឌលបោះឆ្នោតត្រូវបានបញ្ឈប់នោះ បុគ្គលិកនឹងនឹងភ្លាមៗរក្សាឲ្យបាននូវសន្តិសុខដែលបរិក្ខារបោះឆ្នោតនិងគណនីសម្រាប់ឯកសារបោះឆ្នោតទាំងអស់ស្របទៅតាមក្រមបោះឆ្នោតរដ្ឋកាលីហ្វ័រញ៉ា និងគោលការណ៍ណែនាំផលិតសន្លឹកឆ្នោតនិងការបិទបញ្ចប់។ ROV នឹងមានបំណងបើកមណ្ឌលបោះឆ្នោតជំនួសថ្មីមួយនិងប្រើធនធានទាំងអស់សមស្របដើម្បីធ្វើការជូនដំណឹងជាសាធារណៈពីការផ្លាស់ប្តូរនេះ។

ប្រសិនបើមានបរិក្ខារណាមួយត្រូវបានចោរលួច ឬត្រូវបានអុកឡុកនៅមណ្ឌលបោះឆ្នោតណាមួយនោះ បរិក្ខារជំនួសថ្មីនឹងត្រូវបញ្ជូន។ បរិក្ខារដែលត្រូវបានចោរលួច នឹងជាការខាតបង់ផ្នែកហិរញ្ញវត្ថុចំពោះខោនធី Sonoma ប៉ុន្តែនឹងមិនបំផ្លាញដល់សុចរិតភាពនៃការបោះឆ្នោតទេ។ ពុំមានព័ត៌មានអ្នកបោះឆ្នោតនៅសល់លើឡែបថបចុះឈ្មោះ និងភ័ស្តុតាងបញ្ជាក់ពហុឯកតាត្រូវបានតម្រូវដើម្បីធ្វើការផ្លាស់ប្តូរទៅដល់ឧបករណ៍គូសលើសន្លឹកឆ្នោតដែលអាចទទួលបាន ឬម៉ាស៊ីនព្រីនសន្លឹកឆ្នោតចល័ត។

គោលការណ៍ណែនាំពីប្លង់គំរូនឹងត្រូវប្រើប្រាស់ដើម្បីធានាដល់បន្ទប់បោះឆ្នោត និងឧបករណ៍គូសសន្លឹកឆ្នោតដែលអាចប្រើបានត្រូវបានដាក់តាមកន្លែងក្នុងលក្ខណៈដែលអនុញ្ញាតដល់អ្នកបោះឆ្នោតឲ្យគូសលើសន្លឹកឆ្នោតរបស់គេដោយឯករាជ្យនិងដោយមានឯកជនភាព។ ប្លង់គំរូនឹងប្រែប្រួលទៅតាមតម្រូវការការទទួកបានរបស់អ្នកបោះឆ្នោត ហើយនឹងត្រូវកែតម្រូវដើម្បីឲ្យទទួយកបានតាមរូបរាងផ្សេងៗ និងទំហំបន្ទប់នៃទីតាំងនីមួយៗ។ ប្លង់គំរូអាចរកបាននៅក្នុងឧបសម្ព័ន្ធ E.

ROV បានវាយតម្លៃពីភាពចាំបាច់នៃមណ្ឌលបោះឆ្នោតចល័ត និងក្នុងករណីដែលមានគ្រោះមហន្តរាយធម្មជាតិ ដូចជាអគ្គិភ័យ ឬទឹកជំនន់ គួរធ្វើការជាមួយផ្នែកគ្រប់គ្រងគ្រាអាសន្នដើម្បីធានាបាននូវតង់ ប្រសិនបើចាំបាច់។ ROV បានទិញតាមរយៈថវិការរដ្ឋាភិបាល ម៉ាស៊ីនភ្លើងទុកបំរុងដែលអាចផ្តល់ភ្លើងបណ្តោះអាសន្ន ឬ ទីតាំងមណ្ឌលបោះឆ្នោតបន្ទាន់ ប្រសិនបើចាំបាច់។ ROV នឹងបន្តជួយដល់ការបញ្ជូនត្រឡប់មកវិញនៃសន្លឹឆ្នោតតាមសំបុត្រ ហិបទម្លា

ក់សន្លឹកឆ្នោត ជំនួយបច្ចេកទេស សម្រួចលំដាប់បញ្ហាប្រឈមរបស់មណ្ឌលបោះឆ្នោត និងផ្តល់សេវាអតិថិជនក្នុងការិយាល័យក្នុងអំឡុងពេលបោះឆ្នោតនីមួយៗ។

បញ្ជីនៃទីតាំងមណ្ឌលបោះឆ្នោតដែលត្រូវបានបញ្ជាក់ពីចំនួនម៉ោងប្រតិបត្តិការ អាចរកឃើញនៅក្នុងឧបសម្ព័ន្ធ G។ ផែនទីមណ្ឌលបោះឆ្នោតអាចដាក់ចូលទៅក្នុងឧបសម្ព័ន្ធ I។

ព័ត៌មានបន្ថែមស្តីពី ROV និងសន្តិសុខមណ្ឌលបោះឆ្នោត អាចរកឃើញនៅក្នុងសន្តិសុខការបោះឆ្នោតនិងផែនសកម្មភាព (ត្រូវបានព្រាងនៅពេលដែលទីតាំងត្រូវបានកំណត់ភ្លាម)។

4. *ហិបទម្លាក់សន្លឹកឆ្នោត*

អ្នកបោះឆ្នោតនៅទូទាំងរដ្ឋអាចទម្លាក់សន្លឹកឆ្នោតរបស់ខ្លួនដែលបានបោះនៅតាមទីតាំងហិបទម្លាក់សន្លឹកឆ្នោតណាមួយនៅក្នុងរដ្ឋក្នុងអំឡុងម៉ោងប្រតិបត្តិការផ្សាយជាសាធារណៈ។ ការជំនួសសន្លឹកឆ្នោតថ្មីមិនមានផ្តល់ជូននៅតាមហិបទម្លាក់សន្លឹកឆ្នោតឡើយ។ អ្នកបោះឆ្នោតទាំងឡាយអាចតែយកត្រឡប់មកវិញនូវសន្លឹកឆ្នោតទៅកាន់ទីតាំងទាំងនេះក្នុងអំឡុងម៉ោងប្រតិបត្តិការរបស់ទីតាំង ដូចមានផ្សព្វផ្សាយជាសាធារណៈនៅក្នុងសៀវភៅណែនាំព័ត៌មានអ្នកបោះឆ្នោតក្នុងខោនធី កញ្ចប់បោះឆ្នោតបោះតាមសំបុត្រ និងនៅលើគេហទំព័រ ROV។ ហិបទម្លាក់សន្លឹកឆ្នោតដែលអាចបើករថយន្តចូលបានបើក 24 មាននៅការិយាល័យរបស់ ROV, 435 Fiscal Drive, ក្នុង Santa Rosa។

បញ្ជីឈ្មោះទីតាំងបញ្ជាក់ហិបទម្លាក់សន្លឹកឆ្នោតដោយមានម៉ោងប្រតិបត្តិការអាចរកបាននៅក្នុងផែនទីហិបទម្លាក់សន្លឹកឆ្នោតនៃឧបសម្ព័ន្ធ H. អាចដាក់នៅក្នុងឧបសម្ព័ន្ធ I។

## D. ការបណ្តុះបណ្តាលបុគ្គលិកមណ្ឌលបោះឆ្នោត (អ្នកធ្វើការតាមកន្លែងបោះឆ្នោត)

បុគ្គលិកទាំងអស់ រួមទាំងអ្នកទាំងនោះដែលកំពុងធ្វើការនៅតាមមណ្ឌលបោះឆ្នោត និងអ្នកទាំងនោះដែលកំពុងផ្តល់ជំនួយបច្ចេកទេស និងអនុលោមភាព នឹងចូលរួមការបណ្តុះបណ្តាលពីការប្រតិបត្តិការបរិក្ខារបោះឆ្នោត ការរៀបចំមណ្ឌលបោះឆ្នោត ជួយនិងដំណើរការអ្នកបោះឆ្នោត រក្សាសន្តិសុខបរិក្ខារងាយបាត់បង់នៅពេលបោះឆ្នោតពេលយប់ម្តងៗ និងនីតិវិធីសមស្របក្នុងករណីមន្ទាន់។

ROV បានរៀបចំការបណ្តុះបណ្តាលតាមអនឡាញទៅដល់បុគ្គលិកទីតាំងបោះឆ្នោតសម្រាប់ការបោះឆ្នោតខែវិច្ឆិកាឆ្នាំ 2020 ក៏ដូចជាសម្រាប់ការបោះឆ្នោតពិសេសថ្ងៃ2 មីនា 2021

និងយល់ថាការបណ្តុះបណ្តាល់តាមអនឡាញជាឧបករណ៍ដ៏ជោគជ័យមួយសម្រាប់ការបណ្តុះបណ្តាលបុគ្គលិកទីតាំងបោះឆ្នោត និងអាចពិចារណារៀបចំការបណ្តុះបណ្តាលអនឡាញជាចង្កោមនៅក្នុងការបោះឆ្នោតនាពេលអនាគត់។

## IV. <u>សកម្មភាពក្រោយការបោះឆ្នោត – សាធារណជនអាចសង្កេតដំណើរការបោះឆ្នោតណាមួយក៏បាន</u>

### A. ការពិនិត្យនិងរាប់សន្លឹកឆ្នោត – បោះតាមសំបុត្រ

ROV នឹងចាប់ផ្តើមដំណើរការប្រគល់សន្លឹកឆ្នោតបោះតាមសំបុត្រ ដែលរួមបញ្ចូលនូវការដកចេញឬការពិនិត្យឡើងវិញនូវសន្លឹកឆ្នោតផ្លូវការពីស្រោមសំបុត្រនៃសន្លឹកឆ្នោតបោះតាមសំបុត្រផងដែរ និងចាប់ផ្តើមការថតចម្លងសន្លឹកឆ្នោតដែលបានខូច ទៅតាមការចាំបាច់ ឲ្យបានឆាប់តាមច្បាប់បានអនុញ្ញាត។ សន្លឹកឆ្នោតដែលត្រូវបានផ្ញើត្រឡប់មកវិញនៅមុនថ្ងៃសុក្រមុនថ្ងៃបោះឆ្នោត ត្រូវបានដាក់បញ្ចូលទៅក្នុងលទ្ធផលបឋមយប់បោះឆ្នោតចេញផ្សាយភ្លាមៗក្រោយម៉ោង 8:00 យប់។

ស្រោមសំបុត្រសន្លឹកឆ្នោតបោះតាមសំបុត្រដែលបានផ្ញើត្រឡប់មកនីមួយៗ ត្រូវបានដំណើរការតាមរយៈឧបករណ៍តម្រៀបសំបុត្រដែលចាប់ផ្តើមកិច្ចដំណើរការផ្ទៀងផ្ទាត់ហត្ថលេខាសន្លឹកឆ្នោត។ ដំណើរការនេះ ថតយកស្រោមសំបុត្រ ដោយមានហត្ថលេខាអ្នកបោះឆ្នោតសម្រាប់បុគ្គលិកប្រៀបធៀបហត្ថលេខលើស្រោមសំបុត្រទៅនឹងហត្ថលេខលើការចុះឈ្មោះរបស់អ្នកបោះឆ្នោត ឬ ឯកសារគាំទ្រផ្សេងទៀត។ ប្រសិនបើអ្នកបោះឆ្នោតភ្លេចចុះហត្ថលេខាស្រោមសំបុត្រផ្ញើត្រឡប់មក ឬ ហត្ថលេខាមិនត្រូវទៅតាមសំណុំឯកសារអ្នកបោះឆ្នោតនោះ លេខិតនិងទម្រង់មួយត្រូវបានផ្ញើទៅកាន់អ្នកបោះឆ្នោតស្នើសុំហត្ថលេខថ្មី។

នៅពេលហត្ថលេខាត្រូវបានកំណត់ថាមានសុពលភាពនោះ ស្ថានភាពរបស់អ្នកបោះឆ្នោតត្រូវបានធ្វើបច្ចុប្បន្នភាព និងមាននៅលើ [បញ្ជីសន្លឹកឆ្នោតបោះតាមសំបុត្រ។](#) ស្រោមសំបុត្រសន្លឹកឆ្នោតនៅពេលនោះត្រូវបានយកទៅទុកក្នុងឃ្លាំង ដែលបុគ្គលិកទាញចេញសន្លឹកឆ្នោតពីស្រោមសំបុត្រកំណត់ដោយប្រើប្រាស់ដំណើរការស្វ័យប្រវត្តិ បង្កើនជាអតិបរមានូវឯកជនភាពរបស់អ្នកបោះឆ្នោត។ ក្រោយការទាញចេញ សន្លឹកឆ្នោតត្រូវបានប្តូរទៅកាន់បន្ទប់ដំណើរការ ដែលក្រុមការងារពិនិត្យសន្លឹកឆ្នោតរកមើលការខូចខាត និងរៀបចំវាសម្រាប់បញ្ចូលក្នុងតារាងបញ្ជី។ សន្លឹកឆ្នោតដែលខូចខាត ដែលនឹងមិនត្រូវឆ្លងកាត់ម៉ាស៊ីនតារាងបញ្ជីត្រូវបានរៀបចំឡើងវិញដោយក្រុមការងារមានគ្នាពីរនាក់។ ពួកគេគូសតាមលំដាប់លំដោយ ជា "សន្លឹកឆ្នោតថតចម្លង #X" និងជា

"សន្លឹកឆ្នោតដើម #X" និងត្រូវបានរក្សាទុកដាក់ជាមួយនឹងឯកសារបោះឆ្នោតផ្សេងទៀតសម្រាប់រយៈពេលរក្សាទុកតាមលក្ខខណ្ឌតម្រូវ។

ក្រោយធ្វើដំណើរការ ប័ណ្ណសន្លឹកឆ្នោតទាំងឡាយត្រូវបានបញ្ជូនតាមម៉ាស៊ីនបញ្ជីអ្នកបោះឆ្នោត។ រូបភាពដែលស្កេនសន្លឹកឆ្នោត អាចត្រូវបញ្ជូនទៅកាន់កន្លែងវិនិច្ឆ័យដែលមានមនុស្សពីរនាក់វិភាគរូបភាពសន្លឹកឆ្នោត ដើម្បីកំណត់ចេតនាអ្នកបោះឆ្នោត ដោយពិនិត្យឡើងវិញនូវសញ្ញាដែលមន្ទិលរង្វង់មិនត្រូវបានបំពេញត្រឹមត្រូវ កំហុសទាំងឡាយ និងការសរសេរថែមនានា។ បេក្ខជនដែលត្រូវបានសរសេរចូលមានលក្ខណៈសមស្របនោះ ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីវិនិច្ឆ័យ មុននឹងចាប់ផ្តើមដំណើរការវិនិច្ឆ័យសន្លឹកឆ្នោត និងនឹងឆ្លុះបញ្ចាំងពីហិបទម្លាក់សន្លឹកឆ្នោតសម្រាប់ការជ្រើសរើសបេក្ខជនសមស្របដោយក្រុមវិនិច្ឆ័យ។ ប្រសិនបើមានសំណួរពីសន្លឹកឆ្នោតជាក់លាក់ ដែលតម្រូវឲ្យមានការពិនិត្យក្រិតខ្ពស់ ក្រុមវិនិច្ឆ័យនឹង "ធ្វើចត្តាឡីស័ក" សន្លឹកឆ្នោត។ សន្លឹកឆ្នោតដែលត្រូវបានធ្វើចត្តាឡីស័ក ពេលនោះត្រូវបានធ្វើឡើងវិញដោយអ្នកសម្របសម្រួលនាយកដ្ឋានប្រព័ន្ធព័ត៌មានសម្រាប់ការសម្រេចចិត្តជាចុងក្រោយ។

ក្រោយពីបញ្ចូលក្នុងតារាង ក្រដាសសន្លឹកឆ្នោតត្រូវបានរក្សាទុកនៅក្នុងបន្ទប់ដែលមានសន្តិសុខក្រោមកាំម៉េរ៉ាសុវត្ថិភាព 24 ម៉ោង និងអាចត្រូវពិនិត្យឡើងវិញនៅពេលណាមួយក្នុងអំឡុងការបញ្ជាក់ ឬ រយៈពេលរាប់ឡើងវិញ។

*ROV ធ្វើការដោយប្រុងប្រយ័ត្ន ដើម្បីការពារសុចរិតភាពនៃដំណើរការបោះឆ្នោតក្នុងខណៈធានាពីភាពត្រឹមត្រូវនិងឯកជនភាពអ្នកបោះឆ្នោត។ វាប្រើពេលដើម្បីធានា គ្រប់ពលរដ្ឋមានសិទ្ធិបោះឆ្នោតទាំងអស់ បោះឆ្នោតទៅតាមការបោះឆ្នោត លទ្ធលត្រូវបានធ្វើបច្ចុប្បន្នភាពទៅតាមពេលកំណត់ជាក់លាក់ពេញមួយរយៈពេលបូកសរុបនិងរាប់សន្លឹកឆ្នោតនោះ។ អ្នកបោះឆ្នោតអាចពិនិត្យមើលស្ថានភាពសន្លឹកឆ្នោតរបស់គេបានតាម[គេហទំព័រមើលស្ថានភាពអ្នកបោះឆ្នោតរបស់ខ្ញុំ](#)ឬចុះឈ្មោះសម្រាប់តាមដានសន្លឹកឆ្នោតតាម [wheresmyballot.sos.ca.gov](https://wheresmyballot.sos.ca.gov)។*

## B. ការឃោសនារកសម្លេងឆ្នោត - បណ្តាមណ្ឌលបោះឆ្នោត

មួយយប់ៗ បុគ្គលិកមណ្ឌលបោះឆ្នោតនឹងបញ្ជូនឯកសារដែលបានកំណត់ទៅកាន់មណ្ឌលទទួលដែលបានកំណត់។ បុគ្គលិកមណ្ឌលទទួល នឹងប្រមូលឯកសារពីបុគ្គលិកមណ្ឌលបោះឆ្នោត និងធានា អ្វីៗត្រូវបានកត់ត្រាទុកត្រឹមត្រូវ។ បុគ្គលិកមណ្ឌលទទួល ពេលនោះនឹងបញ្ជូនឯកសារពីមណ្ឌលបោះឆ្នោតដែលត្រូវបានកំណត់របស់គេត្រឡប់ទៅវិញទៅកាន់ការិយាល័យ ROV។

ស្បោងដែលមានបិទស្លាកពណ៌ខៀវទាំងអស់ ដែលមានផ្ទុកនូវសន្លឹកឆ្នោតបោះតាមសំបុត្រត្រូវបានផ្ញើត្រឡប់មកវិញ ហិប-A ដែលផ្ទុកសន្លឹកឆ្នោតដែលត្រូវបានបោះដោយមកផ្ទាល់ ស្បោងបិទស្លាកពណ៌ផ្កាឈូក ដែលមានផ្ទុកការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌ និងសន្លឹកឆ្នោតបណ្ដោះអាំសន្ន (ស្រោមសំបុត្រពណ៌ផ្កាឈូក) ស្បោងបិទស្លាកពណ៌លឿង ដែលផ្ទុកបញ្ជីឈ្មោះប្រចាំថ្ងៃ បញ្ជីឈ្មោះបន្ថែម និងបញ្ជីឈ្មោះអ្នកបោះឆ្នោតសុំឲ្យគេយកសន្លឹកឆ្នោតមកឲ្យ និងប័ណ្ណចុះឈ្មោះអ្នកបោះឆ្នោតទាំងឡាយដែលបានបញ្ចប់ ត្រូវបានពិនិត្យដោយបុគ្គលិក ROV និងត្រូវបានកត់ត្រា បានរាប់បញ្ចូល។ ស្បោងណាដែលបាត់ នឹងត្រូវរាយការណ៍កាន់ប្រធានគ្រប់គ្រងសន្និធិ។ រួមបញ្ចូលជាមួយនឹងសន្លឹកឆ្នោតដែលបានបោះនៅនឹងមណ្ឌលបោះឆ្នោតក្នុងហិប-A គឺជាលិខិតបញ្ជាក់កញ្ចប់ដែលបានចប់សព្វគ្រប់ និងការបិទភ្ជិតដើម្បីផ្ទៀងផ្ទាត់ពីដំណើរការភស្តុតាង។ ពុំមានព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកបោះឆ្នោតត្រូវបានបន្សល់ទុកនៅតាមមណ្ឌលបោះឆ្នោតចោលពេញមួយយប់ទេ។

មួយយប់ៗ ROVដំណើរការសន្លឹកឆ្នោតបោះដោយមកផ្ទាល់ចេញពីមណ្ឌលបោះឆ្នោត។ ប្រសិនបើមណ្ឌលបោះឆ្នោតរាយការណ៍ថា ហិបឆ្នោតបោះដោយមកផ្ទាល់របស់គេពេញហួសនោះ មន្ត្រីជំនួយតាមគោលដៅនឹងបញ្ជូនមកបន្ថែមនូវហិបសន្លឹកឆ្នោត និងចុះសោរតាមបច្ចេកទេសទៅឲ្យមណ្ឌលបោះឆ្នោត ដើម្បីធានា សន្លឹកឆ្នោតដែលត្រូវបានបោះដោយមកផ្ទាល់ទាំងអស់មានសន្តិសុខ។

សន្លឹកឆ្នោតចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌ និងសន្លឹកឆ្នោតបណ្ដោះអាសន្ននៅតាមមណ្ឌលបោះឆ្នោត ឬ ការិយាល័យ ROV ត្តួកបោះរូវបានដំណើរការជាបឋមដោយធ្វើការបញ្ជាក់ពីលក្ខណៈស្របច្បាប់របស់អ្នកបោះឆ្នោត។ នៅពេលត្រូវបានបញ្ជាក់ភ្លាម ការចុះឈ្មោះរបស់អ្នកបោះឆ្នោតត្រូវបានធ្វើបច្ចុប្បន្នភាព សន្លឹកឆ្នោតត្រូវបានទាញចេញ ដំណើរការនិងបញ្ចូលដូចសន្លឹកឆ្នោតផ្សេងទៀតដែរ។ សន្លឹកឆ្នោតទាំងនេះត្រូវបានរួមបញ្ចូលទៅក្នុងលទ្ធផលផ្លូវការចុងក្រោយ។

## C. 1% ការរាប់ដោយដៃ

ដើម្បីធានា ម៉ាស៊ីនស្កេនសន្លឹកឆ្នោតគណនាត្រឹមត្រូវនោះ ROV ធ្វើការរាប់ដោយដៃ 1% នៃតំបន់បោះឆ្នោតទាំងអស់នៅក្នុងខោនធី Sonoma។ តំបន់ទាំងឡាយត្រូវបានជ្រើសរើសដោយលក្ខណៈចៃដន្យនៅថ្ងៃក្រោយថ្ងៃបោះឆ្នោត។ ការរាប់ដោយដៃត្រូវបានធ្វើឡើងសម្រាប់ទាំងការបោះឆ្នោតតាមសំបុត្រ និងសន្លឹកឆ្នោតនៅតាមមណ្ឌលបោះឆ្នោតដែលត្រូវបានដាក់ចូលបញ្ជី

ពេញមួយរហូតដល់ថ្ងៃបោះឆ្នោត។ ROV ក៏ស្រាវជ្រាវផងដែរពីដំណើរការ និងលទ្ធភាពនៃប្រើប្រាស់សវនកម្មកម្រិតលើហានិភ័យ ដែលជាជម្រើសនាពេលអនាគត់ ជំនួសឲ្យការរាប់ដោយដៃ 1%។